# ការសំភាសន៍របស់ លោកយាយ យៃ ផន

កៈ អ្នកធ្វើការសំភាសន៍ គីម ម៉េង ខៈ អ្នកដែលត្រូវបានគេសំភាសន៍ យៃ ផន

## ការសង្កេបរបស់លោកយាយ យៃ ផន

លោកយាយ យៃ ផនគាត់មានអាយុ ៧៥ឆ្នាំ ក្នុងឆ្នាំ ២០១៨ លោកយាយ យៃ ផនមានភេទស្រីលោកយាយ យៃ ផន រាល់ថ្ងៃនឹងមានបងប្អូនចំនួន៨នាក់ហើយមានប្រុសចំនន្ទ (២) ហើយនឹងស្រី (៦) នាក់ទាំងអស់មានចំនន្ទ៨នាក់លោកយាយ យៃ ផន រាល់ថ្ងៃនឹងលោកយាយគឺជាបងគេទាំងអស់នៅក្នុងជំនោមបងប្អូនចំនួន៨នាក់លោកយាយ យៃ ផនមានទីលំនៅនាពេលបច្ចុប្បន្ន នៅភូមិសំពោងទង ខេត្ត កំពុងស្ពឺ។

កៈ
ចឹងជាដំបូងជំរាសួរលោកយាយខ្ញុំបាទមកពីរខាងសាកលវិទ្យាល័យបីបាយយូនៃសហរដ្ឋអាមេរិចហើយមានការអញ្ជើញដើម្បីមានការសំភាសន៍លោកយាយអំពីពង្សប្រវត្តិតតើលោកយាយអាយអនុញ្ញាត្តិអោយខ្ញុំបាទសំភាសន៍លោកយាយពង្សប្រវត្តិលោកយាយបានដែលរឺទេ???

ខៈ ចាសបាន ៕

កៈ
ចឹងថ្ងៃនេះគឺជាថ្ងៃដែលខ្ញុំបានសំភាសន៍អ្នកមីងគឺជាថ្ងៃទី០១ខែ០៤(មេសា)ឆ្នាំ២០១៨ហើយធ្វើការសំភាសន៍ដោយរូបខ្ញុំបាទឈ្មោះគីមម៉េងហើយនាក់សំភាសន៍អ្នកមីងឈ្មោះលោកយាយ យៃ ផន
ចឹងផ្ដើមឈ្មោះដំបូងខ្ញុំអាចស្គាល់ឈ្មោះរបស់លោកយាយបានដែលរឺទេលោកយាយ???

ខៈ ចាសបានខ្ញុំឈ្មោះ យៃ ផន ហើយត្រគោលរបស់ខ្ញុំនឹង យៃ ហើយឈ្មោះរបស់ខ្ញុំនឹងឈ្មោះ ផន ចឹងហាសចាស៕

កៈ ចឹងលោកយាយយៃមែនដែលទេលោកយាយអូសអត់ទេគឺលោកយាយ ផន ចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកយាយដំបូងនឹងទៅដល់លោកយាយគឺនាមត្រគោលហើយនឹងឈ្មោះពេញរបស់លោកយាយពេញនឹងថាតើលោកយាយមានឈ្មោះអ្វីដែលទៅលោកយាយ???

ខះ ចាសខ្ញុំនឹងមានឈ្មោះនឹងតែម្តងហាសគឺលោកយាយ ឃៃ ផន
នឹងតែម្តងហើយតារបស់ខ្ញុំនឹងគាត់មានឈ្មោះថា តាឃៃ
ហើយចំនែកឈ្មោះរបស់ខ្ញុំនឹងមានឈ្មោះថា ផន៕

កះ បាទហើយឆ្នាំនឹងថាតើលោកយាយមានអាយុប៉ុន្មានឆ្នាំហើយទៅលោកយាយ???

ខះ ចាសឆ្នាំនឹងខ្ញុំមានអាយុ ៧៥ ឆ្នាំហើយចាសខ្ញុំមានអាយុ ៧៥
ឆ្នាំនៅពេលឆ្នាំថ្មីនឹងហាស៕

កះ
បាទចឹងលោកយាយមានអាយុ៧៥ឆ្នាំហើយហើយលោកយាយមានទីកន្លែងកំណើតនៅទីកន្លែងណាដែលទៅលោកយាយ???

ខះ
ចាសខ្ញុំមានទីកន្លែងកំណើតភូមិខាងក្រាងអំពិលហើយនឹងស្រុកសំរោងទងហើយនឹងខេត្តកំពង់ស្ពឺចាសនៅភ្នំចៀលចាសហើយនៅខាងត្បូងភូមិលង់ពពារចាសភូមិលង់ពពារ៕

កះ
បាទហើយចឹងលោកយាយសព្វថ្ងៃនឹងថាតើលោកយាយប្រកបមុខរបបអ្វីដែលទៅលោកយាយ???

ខះ
ចាសនិយាយទៅគឺខ្ញុំមិនបានប្រកបមុខរបបអ្វីនោះទេគឺខ្ញុំនឹងរស់នៅក្នុងវត្តចឹងហាសចាសហេហេហេ៕

កះ បាទហើយចឹងលោកយាយមានបងប្អូនប៉ុន្មាននាក់ដែលទៅលោកយាយ???

ខះ
ចាសខ្ញុំមានបងប្អូនរាល់ថ្ងៃនឹងចំនួន៨នាក់ហើយមានប្រុសចំនន្ទ២ហើយនឹងស្រី៦នាក់ទាំងអស់មានចំនន្ទ៨នាក់ចាស៕

កះ អូរច្រើនគួរសំចឹងលោកយាយមានបានចាំឈ្មោះរបស់ពួកគាត់ដែលរឺទេលោកយាយ???

ខះ
ចាសគឺខ្ញុំនឹងបានស្គាល់គាត់ទាំងអស់នឹងពីព្រោះអីនឹងខ្ញុំគឺជាបងគេទាំងអស់ចឹងហាសចាស៕

កះ
ចឹងចឹងលោកយាយអាចប្រាប់ឈ្មោះរបស់បងប្អូនរបស់លោកយាយទាំងអស់ម្នាក់ម្តងម្នាក់ម្តងបានដែលរឺទេលោកយាយ???

ខ៖
ចាសចឹងខ្ញុំបានប្រាប់ឈ្មោះរបស់ខ្ញុំហើយហើយណាហើយប្អូនរបស់ទី២របស់ខ្ញុំគាត់មាន
ឈ្មោះ យៃ ផុន ហើយប្អូនរបស់ទី៣របស់ខ្ញុំគាត់មានឈ្មោះ យៃ ផន
ហើយប្អូនរបស់ទី៤របស់ខ្ញុំគាត់មានឈ្មោះ យៃ ផូន
ដែលគែបានហៅថាចានទេណាចឹងដាក់យៃ ចាន
ហើយប្អូនរបស់ទី៥របស់ខ្ញុំគាត់មានឈ្មោះ យៃ អឿន (ប្រុស)
ចាសហើយប្អូនរបស់ទី៦របស់ខ្ញុំគាត់មានឈ្មោះ យៃ ផាត់
ហើយប្អូនរបស់ទី៧របស់ខ្ញុំគាត់មានឈ្មោះ យៃ ផិន
ហើយប្អូនរបស់ទី៨របស់ខ្ញុំគាត់មានឈ្មោះ យៃ អាន
នឹងប្រុសហាសនិយាយគឺប្រុស២នាក់ចាសហើយនឹងមានស្រី៦នាក់៕

ក៖
បាទចឹងប្រុស២ហើយនឹងស្រី៦នាក់មែនដែលទេលោកយាយបាទចឹងលោកយាយមានស្វាមីដែលរឺទេលោកយាយ???

ខ៖
ចាសគឺខ្ញុំគ្មានស្វាមីនោះទេចាសនិយាយទៅគឺគ្មាននោះទេចាសនិយាយទៅគឺគាត់ស្លាប់បាត់ហើយចឹងហាសគឺយូរហើយខ្ញុំនឹងក៏បានមករស់នៅវត្តពីមុនកូនរបស់ខ្ញុំនឹងគាត់បួសគឺខ្ញុំនឹងបានមករស់នៅទីកន្លែងនេះចឹងហាសហើយនៅពេលដែលកូនរបស់ខ្ញុំនឹងគាត់បានសឹកចឹងទៅក៏ខ្ញុំបានត្រឡប់ទៅវិញចឹងហាសហើយដល់ពេលចឹងទៅកូនរបស់ខ្ញុំនឹងគេមានប្រពន្ធចឹងទៅកូនហើយខ្ញុំនឹងនិយាយចឹងបានដែលរឺទេហើយនៅពេលដែលគេមានប្រពន្ធហើយនឹងកូនក៏បានរៀបអាពាហ៍ពិពាហ៍នឹងបាន៣ឆ្នាំហើយចឹងក៏បានមានកូនចំនួន១ហើយនៅពេលដែលកូនរបស់ខ្ញុំនឹងកើតបាន២ខែកន្លះចឹងទៅកូនរបស់ខ្ញុំនឹងទៅថតអោយគេចឹងហាសហើយនៅពេលដែលកូនរបស់ខ្ញុំបានត្រឡប់មកពីថតអោយគេហើយចឹងទៅក៏បានជួបគ្រោះថ្នាក់ចរាចរណ៍ស្លាប៉ាត់ទៅចាសចឹងហើយបានជាខ្ញុំនឹងបានមករស់នៅទីវត្តអារាមន៍វិញចឹងហាសហើយនៅពេលដែលយើងនិយាយពេលដែលគាត់បានរស់នៅវត្តពីមុខនឹងអោយខ្ញុំនឹងបានមករស់នៅហើយនឹងធ្វើជាគណាកម្មការអីនឹងហើយខ្ញុំនឹងក៏បានមករស់នៅវិញចាសហើយសព្វថ្ងៃនឹងគឺខ្ញុំបានរស់នៅតែម្នាក់ឯងនោះទេហើយខ្ញុំនឹងក៏គ្មានបងប្អូនហើយនឹងកូនចៅណាមកនៅជាមួយនោះទេគឺខ្ញុំនៅតែម្នាក់ឯងតែម្តងចាសនិយាយទៅគឺខ្ញុំនៅតែម្នាក់ឯងតែម្តង៕

ក៖
បាទចឹងលោកយាយគ្មានស្វាមីនោះទេបាទហើយចឹងឪពុកហើយនឹងម្តាយរបស់លោកយាយគាត់មានឈ្មោះអ្វីដែលទៅលោកយាយ???

ខ៖ ចាសឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះថា ចៅ សែម
ហើយនឹងម្តាយរបស់ខ្ញុំនឹងគាត់មានឈ្មោះ ឡុង

ហើយម្ដាយរបស់ខ្ញុំគាត់យាយសឿងហើយយាយរបស់គាត់មានឈ្មោះថា តាឡុង
អត់ទេគាត់មានឈ្មោះថា ទេព សឿង ចាសនឹងហើយនឹងទេព សឿង វិញហើយនឹងឪពុក
ចាសហើយម្ដាយរបស់ខ្ញុំនឹងគាត់មានឈ្មោះ ទេព
សឿងហើយនឹងឪពុករបស់ខ្ញុំនឹងគាត់មានឈ្មោះ យៃ សឿងចាស ៕

កៈ បាទចឹងគាត់ទាំង២មានអាយុប៉ុន្មានឆ្នាំហើយទៅលោកយាយ???

ខៈ
ចាសនិយាយទៅគឺយើងនឹងមិនជាសូវបានដឹងដែលចឹងហាសពីព្រោះអីនឹងគាត់ទាំង២បានស្លាប់តាំងពីជំនាន់លុនណុលហើយយើងមិនបានគិតណាហើយយើងលូវនឹងបានគិតតែពីរឿងកូនចៅរបស់យើងចឹងហាសហើយនៅពេលដែលកូនបានបាត់បង់ចឹងទៅគឺនៅពេលដែលកូនរបស់យើងមានគ្រោះថ្នាក់មានស្លាប់២នាក់ចឹងហាសនិយាយទៅគឺខ្ញុំបានបាត់បង់អស់២នាក់ចឹងហាសគឺកូនរបស់ខ្ញុំនឹងបានជួបគ្រោះថ្នាក់ដោយជួបម៉ូតូបុកនឹងហើយលូវនឹងមានការភ្លេចអស់ហើយហើយនៅពេលដែលគេសូត្រធម្មអីនឹងគឺកូនរបស់ខ្ញុំនឹងគឺគេមានការភ្លេចមុខហើយនឹងមានការភ្លេចក្រោយចឹងហាសនិយាយទៅគេមិនជាសូវមានការចាំប៉ុន្មាននោះទេចាសហើយនៅពេលដែលដល់ថ្ងៃសល់អីនឹងតតែសួរអីចឹងទៅបានគេដឹងថាថ្ងៃនឹងគឺជាថ្ងៃសល់ចឹងហាសចាសហើយគាត់គឺមិនជាសូវមានការចងចាំច្រើននោះទេអូនចាសយើងមិនជាសូវដឹងច្រើនអីនោះទេពីព្រោះអីនឹងយើងអាលៃតែគិតពីកូនរបស់យើងនឹងដែលពួកគាត់បានស្លាប់អស់២នាក់ហើយចឹងហាសចាស៕

កៈ
បាទលោកយាយចឹងតើលោកយាយកាល់ដែលនៅពីក្មេងអត់មានស្វាមីទេមែនដែលទេលោកយាយ???

ខៈ
ចាសនិយាយទៅកាល់ដែលខ្ញុំនឹងនៅពីក្មេងនឹងគឺខ្ញុំមានឪពុកហើយនឹងម្ដាយរៀបចំហើយនឹងរៀប
ទុកដាក់ចាសគឺខ្ញុំមានតាចាសហើយអាកូនរបស់ខ្ញុំនឹងឯទើបមានកូនហើយនឹងមានចៅនឹងហាសចាស៕

កៈ បាទហើយលោកយាយបានរៀបអាពាហ្វពិពាហ៍នៅឆ្នាំណាដែលទៅលោកយាយ???

ខៈ
ចាសបើលនិយាយពីរឿងរៀបអាពាហ្វពិពាហ៍នៅឆ្នាំណានឹងគឺខ្ញុំនឹងមិនបានស្គាល់តែម្ដងហាសចាស
និយាយពីពេលដែលខ្ញុំពីរឿងរៀបអាពាហ្វពិពាហ៍ថ្ងៃណាហើយនឹងទីបាំរាំងនឹងគឺខ្ញុំនឹងមិនបានដឹងតែម្ដងចាសហើយខ្ញុំនឹងដឹងតែខ្មែរចឹងហាសចាស៕

ក៖
ចាសចឹងតើលោកយាយបានរៀបអាពាហ៍ពិពាហ៍នៅទីកន្លែងណាដែលទៅលោកយាយ???

ខ៖
ចាសគឺខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅស្រុករបស់ខ្ញុំនឹងតែម្តងហាសគឺនៅឃុំត្រាងអំពៅភូមិរកាតចាសលូវនឹងគេបានប្តូរមកនូវក្រោយនឹងគេបានប្តូរទៅជាភូមិពងមាន់ហើយនឹងភូមិរកាតចាសហើយនឹងខេត្តកំពុងស្ពឺដូចគ្នាហាសចាសនឹងហើយចាសហើយប្តីរបស់ខ្ញុំនឹងគឺបានស្លាប់កាល់គាត់នៅក្នុងជំនាន់លុនណុលចឹងហាសចាសពីព្រោះអីនឹងគឺគេបានចាប់គាត់ទៅធ្វើជាទាហ៊ានចឹងហាសហើយនៅពេលដែលគេបានចាប់គាត់ទៅធ្វើជាទាហ៊ាននៅក្នុងជំនាន់នឹងគឺគេបានចាប់គាត់ហើយគេក៏បានយកគាត់នឹងទៅវៃចោលចឹងហាសនៅឯងបឹងប្រលឹតអីណាចាសហើយនៅមហាសាស្រ្តតូឡាអីណារបស់គេនឹងចាសហើយគេទាំងអស់នឹងគេបានយកទៅវៃដែលគេនឹងគឺជាខ្មែរក្រហមហាសហើយគាត់នឹងក៏បានស្លាប់នៅក្នុងជំនាន់ពោលពតនឹងតែម្តងហាសចាស៕

ក៖
បាទហើយនៅពេលដែលលោកយាយបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងស្វាមីរបស់លោកយាយហើយចឹងកាល់ពេលដែលលោកយាយនៅពីក្មេងចឹងទៅថាតើលោកយាយបានរៀបអាពាហ៍ពិពាហ៍ដោយសេចក្តីស្រលាញ់របស់លោកយាយរឺក៏បានរៀបអាពាហ៍ពិពាហ៍ដោយបង្ខំចិត្តដែលទៅលោលកយាយ???

ខ៖
ចាសនៅពេលដែលខ្ញុំបានរៀបអាពាហ៍ពិពាហ៍នឹងគឺខ្ញុំនឹងបានរៀបអាពាហ៍ពិពាហ៍ដោយសេចក្តីស្រលាញ់ទាំងអស់គ្នានឹងតែម្តងគឺគ្មាននាក់មកនឹងបង្ខំយើងនោះទេចាសហើយកូននឹងក៏បានទៅតាមឪពុកម្តាយចឹងហាសចាសនិយាយទៅគឺគ្មាននាក់ណាមកបង្ខំយើងនោះទេចាស៕

ក៖
បាទហើយនៅពេលដែលនៅក្នុងជំនាន់នឹងថាតើគេមានបានជូនអ្វីទៅកាន់លោកយាយដែលរឺទេលោកយាយ???

ខ៖
ចាសមាននៅក្នុងជំនាន់នឹងគឺគេមានជូនដែលតាហើយនៅពេលដែលគេបានជូននឹងគឺគេបានជូនយើងនឹងគឺជាផ្ទះចឹងហាសចាសហើយឪពុកហើយនឹងម្តាយក៏បានធ្វើជាផ្ទះអោយយើងចឹងហាសចាសហើយនៅពេលដែលគេបានធ្វើផ្ទះអីហើយចឹងទៅទើបយើងបានរៀបអាពាហ៍ពិពាហ៍ចឹងទៅចាស៕

ក៖
បាទហើយចឹងគឺគេបានធ្វើជាផ្ទះសំរាប់ជូនជាបណ្ណាលការអោយចឹងទៅមែនដែលទេលោក

យាយហើយនៅពេលដែលគេបានធ្វើផ្ទះចឹងថាតើគេបានធ្វើផ្ទះប៉ុន្មានខ្នងអោយលោកយាយដែលទៅលោកយាយ???

ខ៖ ចាសនៅពេលដែលគេបានធ្វើផ្ទះនឹងអោយយើងបានតែ១ខ្នងនោះទេចាសហើយធ្វើអោយអីអីចឹងហាសនឹងហើយតែលូវគេច្រើនជាប្រើផ្ទះកាតាំងគេប្រើផ្ទះពិតចឹងហាសចាសពីជំនាន់មុខនឹងគឺគេប្រើតែផ្ទះកាតាំងនោះទេចាសនិយាយគឺគេប្រើផ្ទះកាតាំងនឹងហាសចាស់ពីជំនាន់មុខនោះចាសផ្ទះកាតាំងនឹងចាស៕

ក៖
បាទហើយចឹងអរគុណាច្រើនមែនទែនលោកយាយហើយចឹងខ្ញុំនឹងចង់សួរទៅកាន់លោកយាយ១ទៀតថាតើលោកយាយនៅពីក្មេងនឹងថាតើលោកយាយមានបានទៅសិក្សានៅសាលារៀនដែលរឺទេលោកយាយ???

ខ៖
ចាសគឺអត់មាននោះទេចាសគឺខ្ញុំមិនបានទៅរៀននោះទេពីព្រោះអីនឹងគឺខ្ញុំនឹងបងគេហើយយ៉ាងទៀតនោះគឺឪពុករបស់ខ្ញុំនឹងគាត់គឺជាអ្នកនាក់ដើរលេងភ្លេងអោយគេចឹងហាសចាសហើយនឹងប្រពៃណីហើយនឹងពិធីការចឹងហាសហើយសំរាប់ខ្ញុំនឹងគឺធ្វើការច្រូតហើយនឹងស្ទូងហើយនឹងដកហើយនឹងបានបោកកាដាប់ចឹងទៅចាសនៅតាមវាលស្រែចឹងទៅហាសនឹងហើយគឺតាមយើងគឺជាអ្នកស្រែចឹងទៅហាសចាសគឺជាកម្មករអ្នកស្រែនឹងហើយយើងនឹងធ្វើសព្វគ្រាប់ចឹងទៅចាសហើយខ្ញុំនឹងហាត់គ្រាប់បែបយ៉ាងតែអត់តែជួលនោះទេចាសនឹងហើយខ្ញុំនឹងគឺអត់ចេះជួលនោះទេចាសហើយនៅពេលដែលខ្ញុំនឹងមិនចេះជួលហើយហើយក៏មិនបានចេះបររទេះទៀតចាសតែប្រសិនជាចងកន្តាប់ហើយនឹងបោកកន្តាប់អីនឹងគឺខ្ញុំនឹងវាចេះហើយនឹងលើកវាលស្រែហើយនឹងបាប់តាមវាលស្រែអីនឹងគឺខ្ញុំនឹងវាចេះហើយនឹងកាប់ព្រៃអីនឹងកាប់អីនឹងគឺខ្ញុំនឹងចេះតែសំរាប់បររទេះហើហាយនឹងជួលនឹងគឺខ្ញុំនឹងវាមិនចេះតែម្តងហាសចាសហើយសំរាប់យើងនឹងជាស្រីនឹងទៅធ្វើអីអីចឹងចឹងហើយគ្រាន់តែជិកស្រះនឹងខ្លាចធ្លាក់ក្តូកហាសចាសនិយាយទៅគឺខ្ញុំនឹងខ្លាចតែម្តងហាសចាសចាសនិយាយទៅគឺខ្ញុំនឹងខ្លាចតែម្តងហាសចាស៕

ក៖
បាទចឹងមូលហេតុអ្វីទៅដែលធ្វើអោយលោកយាយមិនបានទៅសាលាដើម្បីសិក្សាចឹងលោកយាយមកពីបញ្ហាក្រុមគ្រសាររបស់លោកយាយរឺក៏មកពីបញ្ហាអ្វីដែលទៅលោកយាយ???

ខ៖
ចាសមូលហេតុដែលខ្ញុំនឹងមិនបានទៅសាលារៀនដើម្បីសិក្សានឹងគឺមកពីបញ្ហាក្រុមគ្រួសារនឹងហើយយើងនឹងបានទៅជួយក្រុមគ្រួសារទៅជួយដកស្ទូងហើយនឹងដកចឹងហាសចាសហើយលោកឪពុករបស់ខ្ញុំនឹងនៅពេលដែលគាត់មិនបានទៅលេងភ្លេងការអោយគេចឹងទៅគឺគាត់បានទៅជួលរាស់ចឹងទៅហើយសំរាប់យើងនឹងនៅផ្ទះនឹងយើងជួយដកអានឹងចឹងទៅ

ហើយនៅពេលដែលគាត់បានមកដល់វិញអីចឹងគឺគាត់ជួយហើយនៅពេលដែលគាត់បានមកពីលេងភ្លេងការវិញជួយស្ទុងហើយនឹងដកចឹងទៅហាសចាសហើយសំរាប់ប្អូនរបស់ខ្ញុំនឹងវាទើបតែមកក្រោយចឹងទៅហើយនៅពេលដែលបាន១ឆ្នាំរឺក៏២ឆ្នាំហើយដែលនៅពេលដែលពួកវាបានធំចឹងហាសគឺវាបានជួយគៀយគោចាសហើយប្រសិនជានិយាយទៅគឺវាជូលជូតខ្លាំងប្រវត្តរបស់ខ្ញុំនឹងហាសចាសនិយាយទៅតាំងពីកាត់ស្មៅហើយនឹងកាត់អីនឹងនិយាយទៅមួយចប់តែម្តងហាសចាសហើយជាពិសេសនោះគឺទៅកាត់ស្មៅអោយគោហើយនឹងរែកស្មៅនឹងអោយគោទៀតចាសនិយាយទៅដូចខ្ញុំនឹងបាននិយាយចឹងហាសគឺគ្មានតែជួលហើយនឹងបររទេះនោះទេចាសការងាររែកទឹកហើយនឹងកាប់អូសហើយនឹងកាប់ឬស្សីអីនឹងគឺខ្ញុំនឹងមិនដែលបានធ្វើនោះទេចាសនិយាយទៅគឺខ្ញុំនឹងមិនចេះធ្វើទាំងអស់ដែលខ្ញុំនឹងបាននិយាយនោះទេចាស៕

កៈ
បាទបញ្ហាដែលបណ្តាលមកពីលោកយាយមិនបានទៅសាលារៀននោះគឺមកពីបញ្ហាជីវភាពលំបាក

មកពីក្រុមគ្រួសាររបស់លោកយាយមែនដែលទេលោកយាយដែលជាហេតុលោកយាយមិនបានទៅសាលារៀនដើម្បីសិក្សាមែនដែលទេលោកយាយ???

ខៈ
ចាសនិយាយទៅគឺខ្ញុំនឹងពិបាក់តែរឿងហើយប្រសិនជារឿងហូបនឹងគឺមិនជាសូវពិបាក់ប៉ុន្មាននោះទេតែគ្រាន់តែយើងនឹងពិបាក់តែរឿងយ៉ាងនោះទេគឺធ្វើការងារនឹងហើយជាមូលហេតុយើងនឹងមិនបានទៅសាលារៀនចឹងហាសចាស៕

កៈ
បាទហើយចឹងនៅក្នុងជំនាន់នឹងថាតើអ្នកណាដែលជាអ្នកផ្គត់ផ្គង់សំរាប់អោយលោកយាយទៅធ្វើការងាររឺក៏ទៅធ្វើការងារអ្វីដែលផ្សេងនឹងថាតើអ្នកណាដែលជាអ្នកផ្គត់ផ្គង់សំរាប់អោយលោកយាយទៅលោកយាយបាទនៅពេលដែលនៅក្នុងជំនាន់ដែលលោកយាយនៅពីក្មេងហាសលោកយាយ???

ខៈ
ចាសមានពីណានោះទេមានតែឪពុកហើយនឹងម្តាយរបស់ខ្ញុំនឹងដែលគាត់ទាំង២គឺជាអ្នកផ្គត់ផ្គង់សំរាប់អោយទៅធ្វើការងារចឹងហាសចាសគឺមានតែម្តាយហើយនឹងឪពុករបស់ខ្ញុំនោះទេចាសហើយមានតែម្តាយហើយនឹងឪពុករបស់ខ្ញុំនឹងទេដែលគាត់ទាំង២ជួយខ្ញុំនឹងហាសហើយមូលហេតុដែលគាត់មិនបានអោយខ្ញុំនឹងទៅសាលារៀនឹងនឹងគឺយើងនឹងមិនធ្វើការងារហាសហើយគេនឹងធ្វើបានតែថ្ងៃអាទិត្យហើយនៅពេលដែលខុសពីថ្ងៃអាទិត្យនឹងយើងមានអ្នកណាទៅជួយគាត់ទាំង២ដល់ពេលហើយចឹងទៅការងាររបស់គាត់ចប់ចឹងទៅមានដូចជាជួលភ្លេងការអីចឹងទៅគឺគាត់បានទៅលេងភ្លេងអីចឹងទៅហើយមានអ្នកណាដែលដោះ

ស្រាយសំរាប់គ្រួសារមានតែយើងនឹងដែលទៅជួកហើយនឹងចង់កន្ទាប់អីចឹងទៅចាសនិយាយទៅមានតែខ្ញុំនឹងដែលជាអ្នកធ្វើចឹងហាសនឹងហើយ៕

ក៖ បាទហើយចឹងប្អូនប្អូនរបស់លោកយាយវិញគាត់ធ្វើអ្វីដែលទៅលោកយាយ???

ខ៖
ចាសនិយាយទៅប្អូនប្អូនរបស់ខ្ញុំនឹងគឺគាត់ក៏បានជួយធ្វើចឹងដែលគ្រាន់តែវានឹងបានធ្វើតែបន្តិចចឹងហាសហើយវាលាងចានហើយនៅពេលដែលពួកវាបានធ្វើការងារច្រើនអីចឹងគឺពួកវានឹងវាលេះលោះហើយនិយាយទៅវាមិនដូចយើងដែលជាបងគេនោះទេចាសយើងដឹងតែខំគិតហើយនឹងខំគូរចឹងហាសចាសហើយនឹងខំរកនោះទេហើយនៅពេលដែលមានអ្វីដែលជាបន្តិចបន្តួចអីនឹងគឺវាទៅលេងហើយហើយនៅពេលដែលយើងខំប្រដៅវានឹងគឺវាខ្ជិលចឹងហាសចាសគឺមិនបានស្តាប់យើងនោះទេហើយនៅពេលដែលមានអ្វីចឹងទៅគឺយើងនឹងចេះតែធ្វើចឹងទៅចាស៕

ក៖ បាទហើយចឹងលោកយាយមិនចេះអក្សរនោះទេមែនដែលទេលោកយាយ???

ខ៖ ចាសគឺខ្ញុំនឹងមិនបានចេះអក្សរនោះទេនិយាយទៅគឺមិនចេះទេលោក៕

ក៖ បាទហើយចឹងលោកយាយមានចេះភាសាអ្វីក្រៅពីភាសាខ្មែរដែលរឺទេលោកយាយ???

ខ៖
ចាសគឺអត់ចេះនោះទេចាសគឺមិនចេះអីទេគឺខ្ញុំនឹងចេះតែនិយាយតាមធម្មតាអីនឹងហាសចាសបានតែបាំរាំងរាល់ថ្ងៃនឹងទោះបីជានិយាយបាំរាំងនឹងហើយនិយាយទីប៉ុន្មានទីប៉ុន្មានអីនឹងគឺខ្ញុំនឹងមិនបានដឹងនោះទេចាសហើយក៏មិនបានដឹងថាបាំរាំងគេនិយាយថាយ៉ាងមិចនោះដែលចាសនិយាយទៅគឺខ្ញុំនឹងអត់ចេះទេលោកម្ចាស់អើយប្រសិនជាសួរពីរឿងទាំងអស់នឹងគឺខ្ញុំនឹងមិនចេះតែម្តងនិយាយទៅគឺអត់ដឹងអីម៉ងហាសចាសថ្ងៃខែនឹងក៏មិនបានដឹងដែលនិយាយទៅដឹងតែខែរបស់ខ្មែរហើយប្រសិនជាកើតថ្ងៃខែហើយនឹងកើតខែជាមួយពោចអីចឹងទៅតែប្រសិនជាអោយនិយាយហើយនឹងឆ្លើយភាសាបាំរាំងនឹងគឺមិនបានដឹងថាយ៉ាងមិចនោះទេចាសនិយាយទៅគឺអត់ដឹងហើយក៏រកនឹកឃើញនឹងក៏មិនបានដែលចឹងហាសពីព្រោះអីនឹងគឺយើងអត់ចេះហើយនឹងមិនបានដឹងពីព្រោះអីយើងមិនបានទៅសាលារៀនហាសតែប្រសិនជាយើងនឹងបានរៀនបានសូត្រអីនឹងទើបយើងនឹងបានដឹងចឹងហាសចាសដល់ពេលដែលយើងមិនបានទៅសាលារៀនចឹងទៅគឺយើង១០គត់ហើយគឺគ្មានដឹងអ្វីនោះទេចាសនិយាយអត់ទេហើយនឹងធ្វើអ្វីនឹងក៏មិនបានត្រូវដែលចឹងហាសនិយាយវាចឹងហាស៕

ក៖
បាទហើយចឹងលោកយាយនៅក្នុងជំនាន់នឹងលោកយាយគឺមិនបានទៅសាលារៀននោះទេបាទហើយជាពិសេសនោះលោកយាយមានជីវភាពពិបាក់ខ្លាំងមែនទែននៅក្នុងក្រុមគ្រួសាររបស់លោកយាយហើយយ៉ាងនោះលោកយាយគឺជាកូនបងគេទៀតនិយាយទៅលោកយា

យគឺជាសសរមួយនៅក្នុងក្រុមគ្រួសាររបស់លោកយាយក្រៅពីឪពុកហើយនឹងម្ដាយរបស់លោកយាយនៅពេលដែលឪពុកហើយនឹងម្ដាយរបស់លោកយាយគាត់បានទៅធ្វើការងារនៅក្រៅចឹងហាសចឹងខ្ញុំចង់សួរទៅកាន់លោកយាយទៀតថាតើនៅពេលដែលឪពុកហើយនឹងម្ដាយរបស់លោកយាយបានចេញទៅខាងក្រៅទៅលេងភ្លេងហើយនៅពេលដែលគាត់បានត្រឡប់មកវិញថាតើគាត់បានជួយធ្វើការងារអ្វីផ្សេងទៀតដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយទៅគាត់បានជួយតានៅពេលដែលខែជ្ចូលរាស់ចឹងទៅដូចជាចេញមុខទៅថ្ងៃនឹងគឺគាត់បានអោយយើងនឹងបានដកថ្ងៃនឹងដកកន្ដាប់ដូចជា២យប់អោយយើងចេញចឹងហាសហើយស្អែកគាត់មកវិញពីលេងភ្លេងចឹងខាងស្អែកនឹងគាត់នឹងបានធ្វើការងារអោយយើងទៀតចឹងហាសចាសហើយសំរាប់ខែជ្រូ្ចកចឹងដែលយើងនៅចឹងទៅគឺយើងនឹងចេះតែច្រូតចឹងទៅហើយនៅពេលដែលគាត់បានមកវិញចចឹងហាសគឺគាត់នបានជួយច្រូតហើយនឹងជួយចងយើងចឹងទៅហើយមានពេលខ្លះចឹងទៅគាត់បានជួយដឹកកន្ដាប់អោយយើងចឹងទៅពីព្រោះអីនឹងគឺមានតែគាត់នោះទេដែលជាជួយដឹកហើយនឹងបោកកន្ដាប់ចឹងហាសពីព្រោះអីនឹងគាត់គឺជាប្រុសចឹងហាសចាសពីព្រោះអីនឹងគាត់ចេះហើយសំរាប់ខ្ញុំនឹងបានតែចងហើយនឹងជញ្ចូលអោយគាត់ដាក់លើរទេះចឹងហាសចាសនិយាយទៅគឺខ្ញុំនឹងមិនជាសូវចេះអីទេគឺខ្ញុំនឹងខ្លាចឆ្លើងខ្លាំងណាស់ចាសហើយគ្រាន់តែជិះម៉ូតូនឹងគឺខ្ញុំនឹងជិះម៉ូតូរបស់ចៅចៅនឹងហាសហើយនឹងដើរទៅផ្សារអីនឹងគឺខ្ញុំនឹងគឺខ្ញុំនឹងបានប្រាប់គេថាអើឯងនឹងកុំចេះម៉ូតូលឿងពេកអញនឹងវាខ្លាចណាស់ចាសហើយប្រសិនជាដល់ថ្នលទទឹងអីនឹងគឺខ្ញុំនឹងដើរទាល់តែដល់ហាសចាសពីព្រោះអីនឹងខ្ញុំខ្លាចដែលចឹងហាសចឹងខ្ញុំនឹងសុខចិត្តដើរទាល់តែដល់ហាសចាសនិយាយទៅគឺខ្ញុំនឹងសុខចិត្តដើរទាល់តែដល់ហាសចាសអត់និយាយច្រើននោះទេចាស៕

ក៖
បាទហើយចឹងអរគុណច្រើនមែនទែនសំរាប់សំណួរទាំងអស់នឹងលោកយាយចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកយាយបន្ថែមទៀតអំពីជីវិតរបស់លោកយាយនៅក្នុយធងជំនាន់ពោលពតវិញម្ដងហាសលោកយាយថាតើនៅក្នុងជំនាន់ពោលពតនឹងលោកយាយរស់នៅទីកន្លែងណាស្រុកណាហើយនឹងខេត្តណាដែលទៅលោកយាយបាទលោកយាយអាចប្រាប់ខ្ញុំបានដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងនៅភូមិដល់ដែលនឹងគឺគ្នាភៀសទៅណានោះទេចាសគឺគេនឹងបានអោយមកស្រុកកំណើតនឹងដ៏ដែលហាសដែលនៅស្រុកពីដើមនឹងហាសចាសគឺពីសង្គមមកនឹងចាសពីមុខនឹងគឺខ្ញុំនឹងបានមកនៅទីកន្លែងនេះពីសង្គមហាសដែលនៅជំនាន់លុនណុលគឺខ្ញុំនឹងនៅវត្តពោត៍វង្សចាសដល់ពេលដែលវៀតណាមមកហាសចាសដល់ពេលដែលខ្មែរក្រហមបានវៃចូលមកចឹងហាសហើយគេបានបញ្ចូលខ្ញុំនឹងមកវិញចឹងហាសដល់ពេល

ដែលហើយចឹងទៅគេបានមកអោយរស់នៅជាមួយនឹងអ្នកស្រុកដែលរស់នៅអូរល្វង់ព្រៃកនឹងហាសចាសអន្លង់សាត់ចាសគឺនៅភូមិចិនដែលគេបានហៅថាហើយខ្ញុំនឹងគឺគ្មានទៅណានោះទេគឺខ្ញុំនឹងគ្មានភៀសខ្លួនទៅណានោះទេចាស៕

កៈ
បាទហើយនៅពេលដែលនៅក្នុងជំនាន់នឹងគឺជាជំនាន់ពោលពតនឹងថាតើលោកយាយហើយនៅស្រុកនឹងថាតើលោកយាយបានឃើញទិតភាពអំពីការបាញ់ដែលគេបានបាញ់ពីសំណាក់ពួកពោលពតចឹងហាសលោកយាយថាតើលោកយាយអាចប្រាប់ខ្ញុំបានដែលរឺទេលោកយាយ???

ខៈ
ចាសនិយាយទៅគឺខ្ញុំនឹងគ្រាន់តែលឺគេនឹងនិយាយតែប៉ុននឹងតែសំរាប់ខ្ញុំនឹងគឺមិនដែលបានឃើញផ្ទាល់នឹងភ្នែកនោះទេចាសពីព្រោះអីនឹងគឺខ្ញុំនឹងគឺជាអ្នកខ្លាចចឹងហាសចាសរាល់ថ្ងៃនឹងគ្រាន់តែខ្ញុំនឹងលឺសំលេងធំធំអីនឹងគឺខ្ញុំនឹងញ្ញាក់សាច់អស់ហើយចាសនិយាយទៅគឺខ្ញុំនឹងខ្លាចណាស់ហើយនៅពេលដែលខ្ញុំឃើញផ្ទាល់នឹងភ្នែកក៏ខ្ញុំនឹងមិនដែលបានឃើញដែលចាសបានជាខ្ញុំនឹងបានឃើញនឹងពួកពោលពតនឹងវានឹងយកទៅវៃចផលចឹងហាសចាសនិយាយទៅគឺនៅពេលដែលគេអោយខ្ញុំនឹងធ្វើអ្វីនឹងគឺខ្ញុំនឹងធ្វើនឹងចឹងហាសចាស

កៈ
បាទហើយចឹងថាតើនៅជំនាន់ពោលពតថាតើលោកយាយមានភាពលំបាក់អ្វីខ្លះដែលទៅលោកយាយអាចប្រាប់ខ្ញុំបានដែលរឺទេលោកយាយ???

ខៈ
ចាសនិយាយទៅគឺខ្ញុំនឹងវាមានភាពលំបាក់ខ្លាំងណាស់ហើយនិយាយគឺខ្ញុំនឹងហូបមិនបានគ្រាប់គ្រាន់ចឹងហាសចាសហើយយើងនឹងបានអ្វីដែលហូបគ្រាប់គ្រាន់និយាយទៅប្រវត្តរបស់ខ្ញុំនឹងគឺខ្ញុំហូបមិនបានគ្រាប់គ្រាន់នោះទេចាសហើយប្រសិនជាស្លររាល់ថ្ងៃនឹងគឺខ្ញុំនឹងបានដាក់បន្លែហើយនឹងត្រកួនហើយនឹងព្រលឹតអីនឹងគឺយើងលាយចូលគ្នាអីចឹងហាសចាសនិយាយគឺដូចជាសព្វជ្រូកចឹងហាសហើយយើងក៏នាំគ្នាស៊ីចឹងហាសហើយនិយាយទៅយើងស៊ីទាំងអស់នឹងទាំងឈឺចឹងហាសហើយនៅពេលដែលខ្ញុំនឹងបានលឺសាច់ជ្រូកចឹងហាសហើយម៉្យាងនឹងគឺយើងមានសុទ្ធតែខ្លាញចឹងហាសហើយនៅពេលដែលខ្ញុំបានលឺដឹកតែឈឺហើយហើយនៅពេលដែលហើយគ្រាន់តែមានខ្លិននឹងក៏ខ្ញុំមានអាម្មរណ៍ថាឈឺដែលចឹងហាសចាសពីព្រោះអីនឹងសាច់អីនឹងនិយាយទៅគឺសុទ្ធតែខ្លាញតែម្តងហាសនិយាយទៅគឺខ្ញុំនឹងគឺដូចជាចាមចឹងគឺខ្ញុំនឹងវាឈឺហាសចាសហើយនៅពេលដែលខ្ញុំនឹងចឹងទៅគឺគេនឹងបានយកខ្ញុំនឹងទៅពេទ្យចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានលឺខ្ញុំបានទៅពេទ្យចឹងគឺខ្ញុំបានគិតថាគឺគេបានយកខ្ញុំនឹងយកទៅវៃចោលហើយចឹងហាសចាសនឹងហើយគឺខ្ញុំបានគិតនៅក្នុងចិត្តរបស់ខ្ញុំនឹងហាសហើយនៅពេលដែលខ្ញុំនឹងបានគិតចឹងគឺខ្ញុំនឹងបានគិតថាគឺគេនឹងបានយកខ្ញុំនឹងយកទៅវៃចោលនៅឯងភូមិដែលនៅខាងត្បូងនឹងហាសហើយខ្ញុំនឹកគិត

ថាគេវៃចោលចឹងហាសចាសគឺខ្ញុំនឹងបានគិតក្នុងចិត្តរបស់ខ្ញុំនឹងហាសចាសនិយាយទៅគឺខ្ញុំនឹងគ្មានវាចារអ្វីនោះទេគឺខ្ញុំនឹងគឺគិតតែនៅស្ងៀមចឹងហាសចាសហើយនៅពេលដែលគេបានដាក់បបរអោយខ្ញុំនឹងបានហូបចឹងគឺខ្ញុំនឹងមិនបាននឹងហូបនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងខ្លាចខ្លាញចឹងហាសចាសគឺខ្ញុំនឹងខ្លាចណាស់ចាសនិយាយទៅដូចថានៅក្នុងជំនាន់នឹងគឺខ្ញុំនឹងមិនសំនឹងជាស្លាប់ចឹងហាសនិយាយទៅគឺជីវិតរបស់ខ្ញុំនឹងមិនត្រូវនឹងអស់ជីវិតចឹងហាសចាសហើយនៅពេលដែលនឹងគឺគេតែតែងអោយខ្ញុំនឹងបានហូបខ្លាញចឹងហាសតែខ្ញុំនឹងនៅតែមិនព្រមហូបចឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានទៅធ្វើការហើយចឹងទៅគឺខ្ញុំនឹងបានទៅដក់ស្ទុងហើយនៅពេលដែលខ្ញុំនឹងបានមកពីដកស្ទុងនឹងគឺខ្ញុំនឹងឈឺតែម្តងចាសហើយនៅពេលដែលខ្ញុំនឹងបានឈឺចឹងគឺខ្ញុំនឹងមានពេទ្យនឹងហើយពេទ្យនឹងគេបានយកម្ទុលវិទ្យាសាស្រ្តគេនឹងយកមកចាក់ខ្ញុំនឹងហាសចាសហើយនៅពេលដែលបានចាក់ខ្ញុំនឹងគឺគេបានចាក់នៅដៃរបស់ខ្ញុំនឹងហើយជើងរបស់ខ្ញុំហើយជាពិសេសនោះគឺគេបានចាក់កំភ្លៅរបស់ខ្ញុំនឹងនិយាយទៅគឺគេបានចាក់ខ្ញុំនឹងគឺសុទ្ធសឹងតែគ្រប់កន្លែងចឹងហាសចាសហើយនៅពេលដែលគេបានចាក់ចឹងគឺខ្ញុំគេបានប្រើម្ទុលវិទ្យាសាស្រ្តរបស់គេចឹងហាសចាសហើយយ៉ាងគេពេទ្យនឹងគេបានសាក់សួរមកខ្ញុំថាហេតុអ្វីបានជាមិត្តឯងនឹងមិនបានហូបសាច់ជ្រូកចឹងហាសហើយមិត្តឯងគឺជាជនជាតិចាមមែនដែលរឺទេហើយនៅពេលដែលគេបានសួរមកកាន់ខ្ញុំចឹងទៅគឺខ្ញុំនឹងបាននិយាយថាគឺខ្ញុំនឹងមិនមែនជាជនជាតិចាមនោះទេចាសហើយសំរាប់ខ្ញុំនឹងគឺជាជនជាតិខ្មែរសុទ្ធហាសហើយខ្ញុំនឹងក៏មិនដែលបានស្គាល់ជនជាតចាមយ៉ាងមិចនោះទេដែលហើយម៉្យាងទៀតក៏ខ្ញុំនឹងមិនដែលបានស្គាល់ជនជាតិនឹងវាបែបមុខនឹងទៅខាងណាដែលហាសចាសហើយនៅពេលដែលគេបានថាចុះប្រសិនជាមិត្តមិនមែនជាជនជាតិថាហេតុអ្វីនឹងមិត្តឯងមិនហូបសាច់ជ្រូកចឹងមិត្តហើយនៅពេលដែលគេបានសួរមកកាន់ខ្ញុំហើយចឹងខ្ញុំនឹងក៏បាននិយាយទៅកាន់គេវិញថាគឺខ្ញុំនឹងមិនដឹងជាយ៉ាងមិចនោះទេគឺខ្ញុំនឹងហូបសាច់នឹងមិនបានតែម្តងហើយអោយតែពេលដែលខ្ញុំនឹងហូបសាច់ជ្រូកគឺខ្ញុំនឹងដឹកតែខ្ញុំនឹងឈឺហើយចាសហើយលូវនឹងខ្ញុំនឹងមិនដឹងជាយ៉ាងមិចចាសហើយនិយាយទៅគឺខ្ញុំនឹងហូមមិនបានចាមហូបមិនបានហើយគេនឹងនៅតែថាអោយខ្ញុំនឹងគឺជាជនជាតិចាមហើយខ្ញុំនឹងនៅតែនិយាយទៀតថាគឺខ្ញុំនឹងគឺជាជនជាតិខ្មែរសុទ្ធទេចាសហើយប្រសិនជាជនជាតិចាមនឹងគឺគេមិនមែននិយាយយ៉ាងដូចចឹងនោះទេហើយគឺគេចេះតែនិយាយអីអីចឹងហាសហើយម៉្យាងទៀតគឺគេតែតែងមកមានដានយើងចឹងហាសចាសហើយនៅពេលដែលមានដីដែលមានស្រុកណាមួយចឹងហាសហើយគេបានទៅគុបទឹកផងហើយនឹងដីផងហើយមាននាក់ខ្លះទៀតគេបានឡើងដើមត្នោតទៀតចឹងហាសចាសហើយនៅពេលដែលគេនឹងបានឡើងទៅចឹងហើយគេបានមកវិញគឺគេចាប់ផ្តើមធ្វើសាច់ជ្រូកស៊ីទៀតចឹងហើយពេលនឹងគេមានបាយហើយនឹងកន្ទេលចឹងហាសចាសបាន១០រឺក៏២០ចឹងតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងខំប្រឹងហើយនឹងខំធ្វើដូចជារ៉ែកដីរ៉ែកអីចឹងហាសចាសហើយប្រសិនជាយើងនឹងមិនខំប្រឹងនឹងធ្វើវាទេខ្លាចគេនឹងវៃយើងចោលទៅនឹងព្រៃចោលចឹងទៅចាសហើយម៉្យាងទៅប្រសិនជាយើងមិនខំប្រឹងនឹងធ្វើទេគឺខ្លាចគេនឹងវៃដោយទាំងបងហើយនឹងទាំងប្អូនរបស់យើងទៀតចឹងហាសចាសនិយាយទៅយើងនឹងចេះតែខំប្រឹងតស៊ូទោះមានស៊ីហើយនឹងអត់មានស៊ីក៏ដោយ

ចេះទេតស៊ូចឹងទៅហាសចាសធ្វើយ៉ាងមិចបើលយើងនឹងកើតមកវាលំបាក់ចឹងហទៅហើយចាសហើយប្រសិនជាយើងនឹងមិនស៊ីទេវាថាយើងនឹងក៏វាមិនកើតហើយប្រសិនជាយើងនឹងថារបស់នឹងវាមិនឆ្ងាញចឹងទៅក៏វាមិនកើតហើយយើងនឹងចេះតែថាឆ្ងាញ់ឆ្ងាញ់នឹងគេចឹងទៅហើយប្រសិនជាយើងនឹងថាមិនឆ្ងាញ់នោះទេគេបានថាមិត្តឯងនឹងអីក៏មានទស្សនាមិចទេចឹងទៅយើងនឹងក៏វាមិនកើតចឹងហាសចាសតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងគឺនៅតែហូបមិនកើតនោះទេចាសតែសំរាប់ខ្ញុំនឹងគឺបានតែបបរនោះទេចាសហើយបបរនឹងគឺខ្ញុំនឹងបានតែទឹកបបរនោះទេហើយយើងនឹងគឺខ្ញុំនឹងចេះតែទ្រាំទ្រាំសិនទៅចាសហើយយើងនឹងចេះតែយកអាសាច់ក្រហមក្រហមនឹងហាសយកមកហូបចឹងទៅចាសហើយនិយាយទៅអោយតាមានសាច់ខ្លាញគឺខ្ញុំនឹងចេះតែយកវាចេញចឹងហាសចាសហើយដូចថាបន្លែលតែគេនឹងច្រូតទាំងសំបកចឹងហាសហើយសំរាប់ដើមចេកនឹងគឺគេនឹងបានកាត់ប្រវែងប្រវែងនេះអីចឹងទៅចាសហើយនិយាយទៅគឺវាមិនសូវជាឆ្ងាញ់អីនោះទេតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងធ្វើវាទាំងអស់នឹងគឺសំរាប់យកទោវត្តចឹងទៅហាសចាសប្រសិនជានិយាយពីប្រវត្តិរបស់ខ្ញុំនឹងគឺវាមានភាពលំបាក់ខ្លាំងណាស់ចាសប្រវត្តិរបស់ខ្ញុំនឹងគឺវាមានភាពលំបាក់ខ្លាំងណាស់៕

ក៖

បាទចឹងនៅពេលដែលលោកយាយបានមានជំងឺចឹងហើយនឹងមានជំងឺផ្សេងផ្សេងចឹងទៅគឺគេបានយកលោកយាយយកទៅពេទ្យចឹងទៅហើយគេបានចាក់ថ្នាំម្ជុលដូចជាវិសាស្រ្តទៅកាន់លោកយាយតែនៅពេលដែលគេបានចាក់ចាក់ថ្នាំម្ជុលទៅកាន់លោកយាយថាតើលោកយាយមានភាពជាបានខ្លះខ្លះដែលរឺទេលោកយាយ???

ខ៖

ចាសនៅពេលដែលគេបានចាក់ខ្ញុំនឹងដោយចាក់ថ្នាំម្ជុលដូចជាវិសាស្រ្តចឹងទៅគឺខ្ញុំនឹងមានឈឺចង្កះចឹងទៅនិយាយទៅនៅពេលដែលយើងបានចាក់ថ្នាំនឹងគឺវាបានធូតែមួយភ្លេចអីចឹងទេដូចថាថ្នាំរបស់គេនឹងគឺវាដូចជាថ្នាំចឹងដូចជាថ្នាំដូចជាដបហើយថ្នាំនឹងគឺគេបានដាក់ដបអោយចឹងហាសចឹងនៅក្នុងជំនាន់នឹងគឺដូចជាគ្រាប់ក្រឡែងបែងនឹងហាសហើយពេទ្យនឹងគេបានមកស្អាយមកមួយកាបូមចឹងទៅហើយគេបានដាក់ដបនឹងហើយដបនឹងគឺគេបានដាក់ជាគ្រាប់ដូចជាគ្រាប់ក្រឡែងបែង

នឹងហាសហើយសំរាប់ខ្ញុំនឹងគឺបានតែថ្នាំដូចជាអាមន៏ទន្សាយចាសជួនកាល់ពេលខ្លះនឹងខ្ញុំនឹងក៏បានញ៉ាំចឹងទៅហើយក៏មានពេលខ្លះនឹងហាក៏ខ្ញុំនឹងមិនបានញ៉ាំទៅហាសចាសហើយនៅពេលនឹងម្តាយរបស់ខ្ញុំនឹងគាត់បានធ្វើការងារដូចជាការដាំបន្លែរហើយនឹងធ្វើចំការអីចឹងហាសចាហើយគាត់បានធ្វើការដាំបន្លែហើយនឹងមានការស្រោចទឹកចឹងហាសហើយម៉្យាងគាត់ក៏បានជួយមើលដំរូបនាងខ្ញុំនឹងចឹងហាសចាសហើយគាត់បាននិយាយមកកាន់ខ្ញុំនឹងថាកុំនិយាយអ្វីដែលមិនល្អណាកូនហើយគាត់ចេះតែសឹបសឹបចឹងហាសចាសហើយគាត់មិនបានអោយខ្ញុំនឹងនិយាយលឺលឺចឹងហាសចាសហើយសំរាប់ខ្ញុំនឹងគឺមានពេលខ្លះនឹងគឺខ្ញុំគឺមិនសូវជាខ្លាចនោះទេចាសពីព្រោះអីនឹងខ្ញុំបានគិតថាយើងទាំងអស់នឹងគឺសុទ្ធតែជាមនុស្សដូចគ្នាចឹងហាសហើយនៅពេលដែលខ្ញុំនឹងគឺមានគេតាមដានចឹងហាសគឺមានពេលខ្លះនឹង

គឺមានឈ្លបចាំតាមដានខ្ញុំនឹងចឹងហាសហើយនៅពេលដែលខ្ញុំនឹងនៅពេលដែលខ្ញុំនឹងគឺខ្ញុំនឹងបានលួចហូបម្ហូបហើយនឹងអាហារចឹងពីព្រោះអីនឹងនៅពេលដែលពេលថ្ងៃចឹងគឺខ្ញុំនឹងមើលទៅមានភាពស្ងប់ស្ងាប់ចឹងទើបខ្ញុំនឹងបានហូបអីចឹងពីព្រោះមានឈ្លបគេនឹងគេបានតាមដានខ្ញុំចឹងហាសចាសហើយសំរាប់ខ្ញុំនឹងមានពេលខ្លះចឹងនៅពេកដែលខ្ញុំនឹងហូបនឹងគឺខ្ញុំនឹងគឺហូបមិនជាសូវបាននោះទេពីព្រោះអីនឹងគឺខ្ញុំនឹងមិនជាសូវស្រួលខ្លួនចឹងហាសចាសនិយាយទៅគឺខ្ញុំនឹងវេទនាណាស់ហ៊ុម៕

ក៖
បាទចឹងនៅពេលដែលលោកយាយនៅក្នុងមន្ទីពេទ្យចឹងម្ដាយរបស់លោកយាយដែលគាត់បានជួយផ្ដល់ម្ហូបដែលលោកយាយចូលចិត្តហូបចឹងថាគាត់មានភាពលំបាក់អ្វីដែលទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺមានតែគ្រប់នឹងនោះទេហើយគ្រប់នឹងគឺជាគ្រប់ក្រគោចឹងហាសចាហើយអាគ្រប់ក្រគោនឹងហើយវាវែងវែងនឹងហាសហើយគាត់ដាក់អោយចឹងហើយគាត់បានដាំជាមួយនឹងតាតានឹងហាសហើយនៅពេលដែលខ្ញុំនឹងគឺបានសុំគេហើយពេលនឹងគឺម្ដាយរបស់ខ្ញុំនឹងគឺគាត់បានសុំគេអោយបានគ្រប់នឹងយកទៅធ្វើម្ហូបនឹងមកអោយខ្ញុំនឹងបានហូបអីចឹងហាសហើយខ្ញុំនឹងបានសុំគេនឹងអោយគេនឹងបានដុះហើយនឹងដាក់នឹងក្រមារចឹងហាសពីព្រោះអីនឹងគឺខ្ញុំនឹងមិនជាចង់អោយគេននឹងបានឃើញនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងខ្លាចគេនឹងតិចទៀនយើងចឹងហាសចាសហើយជាពិសេសនឹងគឺខ្លាចគេយកយើងនឹងយកទៅកសាងយើងហាសចាសមានតែបិននឹង៕

ក៖
បាទហើយចឹងនៅពេលដែលលោកយាយបាននៅក្នុងមន្ទីពេទ្យថាតើរយះពេលណាដែលលោកយាយបានជាពីជំងឺសះស្បើយរបស់លោកយាយចឹងហាសលោកយាយ???

ខ៖
ចាសនិយាយទៅវាមិនជាសូវបានប៉ុន្មាននោះទេចៅនិយាយទៅប្រហែលជា២សប្ដាហ៍អីមិនដឹងអីមិនដឹងចឹងហាសហើយខ្ញុំនឹងនៅមិនបានយូរនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងបានឃើញគេនឹងមានចំនួនមនុស្សស្លាប់ចឹងហាសហើយនៅពេលដែលខ្ញុំនឹងឃើញមានចំនួនមនុស្សស្លាប់ច្រើនចឹងទៅគឺខ្ញុំនឹងមានអារម្មណ៍ថាភ័យចឹងហាសហើយនៅពេលដែលខ្ញុំនឹងបានឃើញចឹងក៏ខ្ញុំនឹងបានសុំគ្រូពេទ្យហើយខ្ញុំនឹងបាននិយាយថាអ្នកគ្រូពេទ្យអើយខ្ញុំនឹងសុំចេញវិញហើយចឹងហាសចាសហើយនៅពេលនឹងគេបាននិយាយថាហើហាយមិត្តអីរីក៏មិត្តបងទៅធ្វើការងាររួចដែលមែនដែលរឺទេហើយពេលនឹងខ្ញុំនឹងក៏បានប្រាប់គាត់វិញថាខ្ញុំនឹងអាចធ្វើបានហើយខ្ញុំនឹងចេះតែធ្វើចឹងហាសចាសពីព្រោះអីនឹងរាល់ថ្ងៃមានចំនួនមនុស្សស្លាប់ច្រើនម្លឹងម្លឹងហើយម៉្យាងទៀតមានអ្នកខ្លះនឹងគេក៏បានស្រែកអួយអួយហើយនៅពេលដែលគេបានស្រែកចឹងទៅមានអ្នកខ្លះនឹងគេក៏បានទៅបាត់ចឹងទៅហើយបៅនៅពេលដែលខ្ញុំនឹងបា

នឃើញគេបានស្លាប់ចឹងខ្ញុំនឹងមានអារម្មណ៍ថាភ័យហាសចាសហើយនៅពេលដែលខ្ញុំនឹងបានឃើញចឹងទៅគឺខ្ញុំនឹងក៏បានសុំគេចេញហើយមករកធ្វើការងារជាមួយនឹងគេចឹងទៅ៕

ក៖
បាទចឹងនៅពេលដែលលោកយាយបានទៅធ្វើការងារបន្ថែមទៀតនឹងថាតើលោកយាយមានកំលាំងនឹងធ្វើការងារនឹងដែលរឺទេលោកយាយរឺក៏យ៉ាងមិចដែលទៅលោកយាយរឺក៏លោកយាយធ្វើទាំងឈឺនឹងតែម្តងទៅលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងខំប្រឹងធ្វើទាំងឈឺនឹងហាសហើយប្រសិនជាយើងនឹងមិនធ្វើទេគឺពួកវានឹងនិយាយថាយើងនឹងឈឺតិចក៏ដោយរឺក៏ឈឺច្រើនក៏ដោយក៏វានឹងអោយយើងនឹងខំប្រឹងធ្វើការងារនឹងចឹងហាសចាសហើយនៅពេលដែលយើងធ្វើការងារនឹងបានហើយតែយើងនឹងមិនបានធ្វើចឹងគឺយើងនឹងមិនល្អហើយខ្លាចគេនឹងយកយើងនឹងយកទៅកសាងចឹងហាសហើយណាមួយយើងខ្លាចពួកវានឹងយកយើងនឹងទៅកសាងអីចឹងហាសនិយាយទៅគឺខ្លាចវាយកយើងនឹងយកទៅសំលាប់ចោលអស់មួយពូជរឺក៏មួយអំបូររបស់យើងនឹងហាសចាសហើយវានឹងមិនមែនទ្រំតែសំរាប់យើងនឹងទេគឺពួកវាសំលាប់ទាំងបងទាំងប្អូនរបស់យើងហើយនឹម្តាយរបស់យើងនឹងហើយនឹងឪពុករបស់យើងនឹងហាសនិយាយទៅគឺសំលាប់ទាំងពូជតែម្តងហាសចាសនិយាយទៅគឺសំលាប់ទាំងពូជតែម្តងហាសមែនលេងសើចនោះទេចាស៕

ក៖
បាទហើយចឹងនៅពេលដែលលោកយាយបានចេញពីមន្ទីពេទ្យហើយលោកយាយបានទៅធ្វើការងារដូចជាធ្វើការងារស្ទូងនឹងធ្វើការងារដូចជាកាប់ដីកាប់អីនឹងគឺធ្វើទាំងឈឺហើយគេបានយកលោកយាយទៅសំលាប់អីចឹងមែនដែលទេលោកយាយ???

ខ៖
ចាសអានឹងគឺចឹងហើយតែដោយសារយើងនឹងគឺយើងចង់រស់មានជីវិតតទៅមុខទៀតហើយយើងនឹងចេះតែរកតែមួយរស់ដីហើយនឹងក្បាលហើយអោយបានអ្នកណាហើយនឹងលោកណាដែលគេមានបុណ្យសុំមករំដោះប្រជាជនហើយនឹងប្រជាពលរដ្ឋអោយបានរួចផុសពីកំដាប់ដៃមនុស្សអាក្រកចឹងហាសហើយនៅពេលដែលខ្ញុំនឹងបាននិយាយគឺយើងនឹងមិហ៊ាននិយាយចឹងទេដល់តែពេលដែលយើងនឹងទៅបត់ជើងធំហើយនឹងបត់ជើងតូចចឹងហាសរឺក៏នៅក្នុងព្រៃចឹងទៅបានយើងនឹងហ៊ាននិយាយចេញមកហើយសំរាប់ខ្ញុំនឹងចេះតែថាទៅហើយពាក្យរបស់ខ្ញុំនឹងគឺខ្ញុំនឹងមិនដែលនឹងភ្លេចនោះទេហើយខ្ញុំនឹងបាននិយាយថាអោយតែបានសេចក្តីសុខហើយនឹងមានអ្នកដែលមកបានជួយរំដោះពីទុក្ខទោះនឹងអ្វីក៏ខ្ញុំនឹងហូបបានដែលអោយតែស្រុកនឹងគឺគ្មានសង្រ្គាមហើយនៅពេលដែលខ្ញុំនឹងបាននិយាយចឹងហើយគឺខ្ញុំនឹងមិនដែលបានភ្លេចនោះទេហើយទោះជាអោយខ្ញុំនឹងបានហូបបាយជាមួយនឹងអំបិលនឹងក៏ខ្ញុំនឹងសុខចិត្តដែលចឹងហាសចាសដល់ពីមុខនឹងខ្ញុំនឹងហូបាយជាមួយនឹអំបិលអីនឹ

ងក៏ចេះតែហូបបានដែលទៅចាសនិយាយគឺខ្ញុំនឹងមិនដែលបាននឹងភ្លេចពាក្យដែលខ្ញុំនឹងបាននិយាយកាល់ពីមុននឹងនោះទេចាសហើយើងនៅពេលដែលយើងនឹងបានៅទៅវត្តអីចឹងគឺយើងទីវត្តទៅទៅពីព្រោះអីយើងនឹងគឺគ្មានលុយច្រើននោះទេចាគឺមានតែប៉ុននឹងនិយាយទៅអោយតែបានទៅវត្តចឹងហាសចាស៕

កះ
បាទហើយចឹងថាតើនៅក្នុងជំនាន់ពោលពតនឹងថាតើគេនឹងមានបានអោយលោកយាយធ្វើអ្វីផ្សេងក្រៅពីការងារកាប់ដីរឺក៏អ្វីដែលផ្សេងផ្សេងទៀតដែលរឺទេលោលកយាយ???

ខះ
ចាសគឺគ្មាននោះទេគឺមានតែកាងារដែលកាប់ដីហើយនឹងហើយនឹងមានកាប់ស្លឹកអីចឹងហាសនិយាយទៅគឺជាស្លឹកត្នោតចឹងហាសចាសហើយនៅពេលដែលយើងនឹងបានទៅរស់នៅកងអ្វីនោះទេដែលគេបានហៅកងលុនហាសហើយនៅពេលដែលយើងនឹងបានរស់នៅនោះចឹងគឺគេនឹងបានអោយខ្ញុំនឹងបានធ្វើជាកន្ត្ររហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនចេះធ្វើនោះទេចាសនិយាយទៅគឺខ្ញុំនឹងមិនចេះធ្វើទេហើយដើមដូងហើយនឹងដើមត្នោតដែលមានប្រវែងនឹងវាខ្ពស់ខ្ពស់ចឹងហាសចាសនិយាយទៅដើមដូងដែលមានកំពស់ខ្ពស់អីនឹងខ្ញុំនឹងបានឡើងចាសគឺបានឡើងអោបចឹងហាសគឺឡើងដើម្បីកាប់ស្លឹកពីនាក់ដែលបានទៅធ្វើការងារនឹងហើយម្នាក់នឹងគេបានចងហើយសំរាប់ខ្ញុំនឹងគឺជាអ្នកកាប់ចឹងហាសចាសដើមត្នោតនឹងគឺគេចេះតែដាក់អោយយើងនឹងចាសហើយប្រសិនជាយើងមានជាងច្រូងនឹងគឺយើងនឹងចេះតែជាន់លើនឹងទៅហាសចាសហើយនៅពេលដែលអត់មានជ្រូននៅខាងក្រោមអីចឹងគឺយើងជាន់គេហើយយើងនឹងឡើងទៅលើដើម្បីកាប់វាចឹងទៅចាក់ចាក់អោយគេចឹងទៅហាសហើយនៅពេលដែលហើយយើងនឹងនៅយើងក៏ជ្រៀកក្បាលវាចឹងទៅហើយពេលនឹងគឺយើងនឹងបានធ្វើកន្ទេរហើយនឹងក្រមារសំរាប់អោយកងកុមារអីចឹងទៅចាសនិយាយទៅគឺយើងនឹងធ្វើអោយសំរាប់កងកុមារហើយនឹងធ្វើដោយកន្ទេលដែលធ្វើពីត្នោតចឹងហាសហើយពីដើមយើងនឹងគឺធ្វើកន្ទេលត្នោតចឹងហាសពីដើមយើងនឹងហើយនៅពេលដែលយើងនឹងធ្វើកន្ទេលនឹងគឺយើងនឹងបានដេរដោយស្លឹកវែងវែងនឹងហើយើងនឹងបានធ្វើកន្ទេលត្នោតនឹងទៅហើយហើយយើងបានរ៉ែកហើយនៅពេលដែលយើងនឹងបានរ៉ែកនឹងគឺយើងបានរ៉ែកកន្ទេលមួយចំហៀងចឹងទៅហើយនឹងរ៉ែកអ្វីផ្សេងមួយចំហៀងចឹងទៅហាសចាសដែលមានកន្ទេលហើយនឹងសំភារះផ្សេងផ្សេងចឹងទៅហើយមានពេលខ្លះនឹងគឺយើងនឹងបានដាក់ថ្លងអីចឹងខ្លះចឹងទៅហាស៕

កះ បាទនិយាយទៅលោកយាយចេះឡើងដើមដូងមែនដែលរឺទេលោកយាយ???

ខះ
ចាសគឺខ្ញុំនឹងមិនចេះឡើងដើមដូងនោះទេហើយនឹងដើមត្នោតទេចាសគឺគេនឹងបានឡើងដើមត្នោតហើយនៅជំនាន់នឹងគឺគេនឹងមានគារដើម្បីនឹងឡើងចឹងហាសចាសនឹងនៅពេលដែលគេងអោយនឹងធ្វើបានយើងនឹងធ្វើចឹងហាសហើយនៅពេលដែលយើងនឹងបានឡើងចឹង

គឺគេមានអាគេហៅថាចង្អោងដើម្បីនឹងឡើងទៅចឹងហាសហើយយើងដាក់ចង្អោងដើម្បីនឹងឡើងទៅនិយាយទៅគឺវាដូចជាកាប់ជុនដើរចឹងអាចង្អោងវាជាឬស្សីនឹងហាស៕

កៈ
បាទចឹងខ្ញុំនឹងស្គាល់វាហើយបាទហើយចឹងលោកយាយដែលនៅជំនាន់ពោលពតនឹងថាតើលោកយាយឡើងដើម្បីត្នោតនឹង១ថ្ងៃនឹងចំនួនប៉ុន្មានដងដែលទៅលោកយាយ???

ខៈ
ចាសគឺខ្ញុំនឹងឡើងតែពេលព្រឹកចឹងហាសហើយនៅពេលដែលពេលថ្ងៃនឹងគឺយើងនឹងទៅកន្លែងវិញហើយនឹងបានចាកឆ្បាបអីចឹងទៅហើយមានអ្នកខ្លះចឹងគឺគេបានជៀកស្លឹកចឹងទៅចាសគឺខ្ញុំនឹងឡើងតែពេលព្រឹកទេហើយនៅពេលថ្ងៃចឹងទៅគឺខ្ញុំនឹងមិនបានឡើងនោះទេពីព្រោះអីនឹងគឺយើងនឹងបានមកវិញចឹងគឺដើម្បីមកធ្វើកន្ទេលសំរាប់អោយគេនឹងបានសំរាក់ចឹងហាសចាសនិយាយទៅគឺខ្ញុំនឹងមិនមែនជាអ្នកនឹងធ្វើវានោះទេតែមានគេទេដែលជាអ្នកធ្វើចឹងហាសចាសហើយសំរាប់ខ្ញុំនឹងគ្រាន់តែខ្ញុំនឹងជាអ្នកដែលជួយគេបានតិចតិចចឹងទេចាស៕

កៈ
បាទហើយនៅពេលដែលលោកយាយបានឡើងដើមត្នោតនឹងដើម្បីបេះស្លឹកវារឺក៏នឹងធ្វើអ្វីផ្សេងផ្សេងនឹងហើយនៅពេលដែលលោកយាយអោយបានធ្វើជាកន្ទេលហើយចឹងថាតើលោកយាយបានកន្ទេលទាំងអស់នឹងមកដើម្បីសំរាប់ខ្លួនឯងដែលរឺទេលោកយាយរឺក៏គេនឹងមិនបានអោយកន្ទេលនឹងអោយទៅលោកយាយទេរឺក៏យ៉ាងមិចដែលទៅលោកយាយអាចប្រាប់ខ្ញុំនបានដែលទេ???

ខៈ
ចាសនិយាយទៅគឺមិនបានអោយខ្ញុំនោះទេតែសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនបាននឹងយកវានោះទេចាសពីព្រោះអីនឹងបចនៅពេលដែលនោក្នុងផ្ទះរបស់ខ្ញុំចឹងគឺខ្ញុំនឹងមានក្តារបិននឹងចឹងទៅគឺខ្ញុំនឹងតែតែងដេកហើយនឹងសំរាក់នៅលើក្តារដែលនៅក្នុងផ្ទះរបសខ្ញុំនឹងហាសចាសនិយាយទៅគឺខ្ញុំនឹងគឺខ្ជិលកាន់ហើយនឹងខ្ជិរែកពីព្រោះអីនឹងគឺខ្ញុំនឹងមានសំលៀកបំពាក់ហើយចឹងហាសចាសហើយយើងនឹងមានពាក្យទៅអាថ្មីអាថ្មីអីនឹងពីព្រោះអីនឹងយើងនឹងបានទៅធ្វើការងារដោះកងហើយនឹងដាក់កងហើយនៅពេលដែលយើងនឹងបានទៅចឹងទៅគឺយើងទាំងអស់គ្នានឹងមានផ្តីមានអីចឹងទៅហើយនឹងមានកំសៀវនឹងហើយខ្ញុំនឹងតែតែងដាំទឹកក្តៅសំរាប់នឹងខ្ញុំបានហូបចឹងហាសចាសនិយាយគឺខ្ញុំនឹងហូបទឹកក្តៅហាសចាសហើយនៅពេលដែលខ្ញុំនឹងមានថ្នាំអីនឹងគឺខ្ញុំនឹងចេះតែដាំចឹងទៅនិយាយទៅគឺអោយតែបានក្តៅបានហូបចឹងហាសចាសនិយាយមកយើងធ្វើយ៉ាងមិចគឺយើងធ្វើយ៉ាងអោយយើងនឹងបានហូបអោយបានឆ្អែតចឹងហាសចាសពីព្រោះអីនឹងគឺបើលមិហូបទេយើងនឹងពិបាក់ហើយនឹងអាចស្លាប់តែម្តងចាស៕

ក៖
បាទប៉ុន្មានដែលនៅក្នុងជំនាន់នឹងនៅពេលដែលលោកយាយបានដាំទឹកក្តៅចឹងគឺគេនឹងដែលជាពួកពោលពតនឹងគេមិនបានថាអ្វីទៅកាន់លោកយាយទេមែនដែលទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺពួកពោលពតនឹងគឺវាមិនបានថាអ្វីអោយយើងនោះទេពីព្រោះនឹងមានមនុស្សជាច្រើនណាស់ដែលដាំទឹកក្តៅជាច្រើនសំរាប់ដូចជាយើងចឹងហាសចាសនិយាយមានអ្នកដែលនៅជិតជិតគ្នានឹងហាសហើយនៅពេលដែលមានម្នាក់ដែលគាត់មានជំងឺឈឺគ្រុនចឹងទៅគឺយើងនឹងបានដាំអោយគាត់ហើយគាត់បាននិយាយថាមិត្តបងសុំទឹកតិចណាបានដែលរឺទេហើយនៅពេលនឹងខ្ញុំនឹងក៏បាននិយាយទៅកាន់អ្នកដែលសុំខ្ញុំនឹងថាបងហូបចុះគឺខ្ញុំនឹងមិនចេះចិត្តកំណាញ់អ្វីនោះទេចាសហើយខ្ញុំនឹងគឺខ្ញុំនឹងមិនបានដាំសំរាប់ទុកហូបតែខ្ញុំនោះគឺខ្ញុំនឹងដាំសំរាប់ហូបទាំងអស់គ្នាចឹងហាសចាសហើយពេលនឹងខ្ញុំក៏អោយគាត់នឹងបានហូបចឹងទៅចាសហើយនៅពេលដែលយើងនឹងបានចេញចឹងទៅយើងនឹងបានរ៉ែកហើយនឹងស្ពៀវដាក់មួយចំហៀងចឹងទៅហើយយើងមានចានមួយហើយនឹងស្លាបព្រាមួយចឹងទៅចាសហើយយើងនឹងមានចាន២មកពីណាគឺគេនឹងអោយយើងនឹងបានតែចានមួយសំរាប់ស៊ីនឹងហាសចាសនិយាយទៅគឺមិនមែនជាចានដែលលាយចូលគ្នាទាំងអស់នោះទេចាសនិយាយដូចជាចានសំល្លរបស់គេដែលចឹងហាសចាស៕

ក៖
បាទហើយចឹងនៅក្នុងជំនាន់នឹងគឺជាជំនាន់ពោលពតថាតើគេមានបានអោយលោកយាយបានធ្វើអ្វីបន្ថែមទៀតដែលរឺទេអំពីដែលលំបាក់ជាងនឹងទៀតហាសលោកយាយ???

ខ៖
ចាសនិយាយទៅគឺគ្មាននោះទេគឺមានតែអាដកស្ទុងតែប៉ុននឹងទេអាអាដកស្ទុងអាស្រូវដែលធំហាសហើយនៅពេលដែលគេនឹងបានអោយយើងនឹងធ្វើការងារចឹងគឺគេអោយយើងនឹងដាក់អោយត្រង់ហើយគេនឹងមានខ្សែររបស់គេចឹងហាសនិយាយទៅគឺពិបាក់ណាស់ចៅអើយជីវិតរបស់ខ្ញុំនឹងហាសចាសហើយនៅពេលដែលខ្ញុំនឹងបានរួចពីដូចថាធ្វើអ្វីទេគឺគេនឹងបានអោយយើងនឹងបានចងអ្វីមិនដឹងនោះទេចាសនិយាយវាដូចជាសសរផ្ទះអាសសរបិនបិននេះហើយគេបានកាប់ដូចជាកូនត្នោតហើយគេនឹងធ្វើដូចជាកូនបាយជ្រូលនឹងហើយសំរាប់ខាងបុរសខាងបុរសគេបានធ្វើអីនឹងហើយនៅពេលដែលគេបានជ្រូលអីអីហើយចឹងទៅហើយពេលនឹងគឺគេបានអោយខ្ញុំនឹងបានអូសដូចជាចអ្អួលដូចជាសាច់សាបចាសនៅពេលដែលយើងធ្វើចឹងគេអោយយើងនឹងបានអូសចំងាយនឹងហើយគេអោយយើងនឹងធ្វើយ៉ាងមិចអូសវាអោយត្រង់ចឹងទៅណាចាសនិយាយវាមានចំងាយពីនឹងទៅដល់កូនព្រៃតូចនឹងហាសចាសហើយនៅពេលដែលអូសគឺអូសត្រង់ចឹងទៅហើយមានអ្នកខ្លះនឹងគេចាំសាបក៏ចាំសាបទៅហើយសំរាប់យើងនឹងក៏អូសកាត់ផ្លុសចឹងមកចាសចុះគេទាំងអស់នឹងគេនៅលើភ្លឺគេមានអ្វីហាត់តែសំរាប់យើងនេះទេដែលយើងនឹងនៅក្នុងស្រែនឹងបានយើងជាអ្នកហាត់នោះ

ទេចាសហើយសំរាប់គេនឹងគឺគេចងសំរាប់ប្រុសប្រុសគេចឹងទៅហើយចុះអង្គររបស់គេហើយនៅពេលដែលអង្គររបស់គេនឹងគេបាននិយាយថាមើលអោយមិត្តនារីនឹងអូសហើយនឹងធ្វើជាដើរកាត់ហើយនឹងដួលចឹងហាសហើយសំរាប់យើងនឹងចេះតែអូសចឹងទៅព្វព្រោះអីនឹងមានគេនឹងគេចាំឈរមើលយើងចឹងហាសហើយនៅពេលដែលគេបានឈរមើលចឹងទៅគឺគេនឹងបានអោយនឹងឈរហើយអោយយើងនឹងអូសអោយត្រង់ហើយនឹងដើរអូសចឹងទៅចាស៕

កៈ
បាទហើយនៅពេលដែលលោកយាយបានចុះទៅពីខាងវាលស្រែនឹងគឺដើម្បីស្ទុងថាតើលោកយាយបានចុះតែម្នាក់ឯងរឺក៏មាននាក់ណាដែលទៅចុះជួយលោកយាយដែលទៅលោកយាយ???

ខៈ
ចាសនិយាយទៅគឺមានគ្នាច្រើនណាស់ដែលបានចុះទៅស្ទុងដែលគេមានជាក្រុមចឹងហាសហើយគេដូចជាអោយយើងនឹងចុះមួយកងចឹងទៅចាសនៅពេលដែលគេចុះចឹសងទៅគឺគេមានគ្នាជាក្រុម១០នាក់រឺក៏មានពេលខ្លះក៏មាន២០នាក់អីចឹងទៅចាសនិយាយទៅខ្ញុំនឹងមិនបានទៅតែឯងនោះទេគឺខ្ញុំនឹងគ្នាហើយនឹងក្រុមនឹងគឺយើងទៅទាំងអស់គ្នាចឹងហាសចាសតែសំរាប់តែកាត់ជអួសនោះទេគឺជាខ្ញុំនឹងចឹងហាសចាសនឹងហើយគឺគេបានផ្លាសនារីនារីនឹងយកទៅចាំភ្លឺស្រែចឹងបាន១ហិតាចឹងទៅហាសចាសហើយនៅពេលដែលតាតានឹងគាត់រួសអីហើយចឹងទៅហើយពេលនឹងខ្ញុំនឹងបានចុះរួសហើយណាមួយនឹងគឺខ្ញុំនឹងបានចុះជាមួយគេចឹងទៅដល់ពេលហើយចឹងទៅគឺគេនឹងបានចុះរួសម្នាក់ទៀតចឹងហាសចាស៕

កៈ
បាទហើយចឹងនៅពេលដែលលោកយាយបានចុះរួសអីចឹងម្តងម្តងចឹងថាតើគេលោកយាយគ្រាន់តែជាអ្នកចង់ហើយនឹងដើម្បីយកទៅអោយគេទេមែនដែលទេលោកយាយ???

ខៈ
ចាសនិយាយទៅនៅពេលដែលយើងនឹងបានចុះដកនឹងគឺយើងនឹងត្រូវតែចុះដកទាំងអស់គ្នាចឹងហាសចាសនិយាយទៅដកគឺទាំងអស់គ្នាហើយនៅពេលដែលស្ទុងនឹងគឺយើងត្រូវតែស្ទុងទាំងអស់គ្នាចាស៕

កៈ
បាទចឹងអរគុណាច្រើនលោកយាយហើយចឹងសំណួរដែលខ្ញុំនឹងសួរទៅកាន់លោកយាយមួយទៀតថាតើនៅពេលដែលគេបានបែកពីជំនាន់ពោលពតនឹងថាតើលោកយាយបានរត់ទៅទីកន្លែងណាទៅលោកយាយ???

ខៈ
ចាសនិយាយទៅខ្ញុំបានរត់ទៅគឺខ្ញុំនឹងបានទៅអីណាគេនោះដូចជាទៅណានោះទេពីព្រោះ

អីនឹងគឺគេមិនទាន់បានរំដោះភ្នំពេញនោះទេចាសហើយនៅពេលដែលគេបានរំដោះហើយខ្ញុំនឹងក៏បានរត់ទៅហាង់ត្រនុងនោះចាសហើយនៅពេលដែលខ្ញុំនឹងបានត្រឡប់មកវិញចាសហើយនៅពេលដែលខ្ញនឹងត្រឡប់មកវិញគឺខ្ញុំនឹងបានទៅរស់នៅទ្រង់ពពារភូមិពពារដែលចឹងហាសហើយនៅពេលដែលសំម្តេច ហ៊ុនសែន
គាត់បានទព័នឹងបានមករំដោះហាសដែលនៅល្អងពរពាលនឹងហើយពេលនឹងកងពទ័ជនជាតិវៀតណាមនឹងក៏បានអោយខ្ញុំនឹងឌីឌីឌីឌីឌីចឹងហាសហើយនៅពេលនឹងខ្ញុំនឹងក៏មិនបានដឹងថាពាក្យឌីឌីឌីនឹងវាបានន័យថាយ៉ាងមិចនោះទេចាសហើយពេលនឹងខ្ញុំនឹងចេះតែឈរមេមាំមេមាំហើយពេលនឹងគាត់បានធ្វើដៃនឹងអោយទៅទីកន្លែងនោះចឹងហាសហើយនៅពេលនឹងខ្ញុំនឹងទៅតាមដៃរបស់គាត់ចឹងហាសដែលដៃរបស់គាត់នឹងឌីឌីឌីនឹងហើយនៅពេលដែលធ្វើចឹងទៅគឺខ្ញុំនឹងទៅតាមចឹងហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលគេបានរំដោះហើយលោកយាយបានរស់នៅខេត្តកំពងស្ពឺនឹងតែម្តងមែនដែលទេលោកយាយ?

ខ៖ ចាសខ្ញុំនឹងបានរស់នៅខេត្តកំពងស្ពឺនឹងតែម្តងរំដោះនៅពេលដែលសំម្តេច ហ៊ុនសែន គាត់បានមកនឹងហាសចាស៕

ក៖
បាទហើយនៅពេលដែលលោកយាយបានរួចមកថាតើលោកយាយបានជួបជុំនឹងគ្រួសាររបស់លោកយាយទាំងអស់គ្នាដែលរឺក៏យ៉ាងមិចដែលលោកយាយអាចប្រាប់ខ្ញុំនឹងបានដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងបានជួបជុំនឹងគ្រួសាររបស់ខ្ញុំនឹងគឺកូនរបស់ខ្ញុំហើយនឹងម្តាយរបស់ខ្ញុំនឹងគឺគាត់បានទៅនៅផ្សេងគ្នាហើយសំរាប់ខ្ញុំនឹងនៅផ្សេងពីគ្នាចឹងទៅហាសចាសគឺខ្ញុំនឹងបានរស់នៅជាមួយនឹងកូនរបស់ខ្ញុំនឹងចាស៕

ក៖
បាទហើយហេតុអ្វីដែលទៅដែលលោកយាយមិនបានទៅរស់នៅជាមួយនឹងគ្រួសាររបស់លោកយាយចឹងលោកយាយអាចប្រាប់ខ្ញុំនឹងបានដែលរឺទេលោកយាយ???

ខ៖
ចាសពីព្រោះអីនឹងគាត់ទាំងពីគឺគាត់មានកូនរបស់គាត់ដែលហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមានកូនរបស់ខ្ញុំនឹងដែលចឹងហាសចាសហើយគាត់មានកូនច្រើនហើយដល់ពេលយើងនឹងគឺយើងនៅជាមួយនឹងកូនរបស់យើងចឹងទៅហើយនៅពេលដែលយើងនឹងបានទៅរកអង្ករហើយនឹងកំប៉ុងហើយយើងទាំងអស់នឹងក៏បានរកមុខរបបដូចជាលក់ដូរនេះលក់ដូរនោះចឹងទៅហើយពេលនឹងគឺខ្ញុំនឹងមានលុយអីតែបន្តិចបន្តួចហើយពេលនឹងគឺខ្ញុំនឹងបានរកបានតែ

បន្តិចបន្តួចហើយខ្ញុំនឹងក៏បានរកទិញដូចជាខ្ទឹមហើយនឹងបីចេងចឹងទៅហើយយើងនឹងក៏ឧស្សាហ៍ឈឺចឹងហាសចាសពីព្រោះអីនឹងនៅក្នុងជំនាន់នឹងគឺយើងនឹងដើរចឹងហាសចាសហើយពេលនឹងគឺខ្ញុំនឹងបានលក់ដូរបានប្ដូរយកជាអង្ករចឹងទៅដែលដើរតាមភូមិចឹងហាសចាសហើយនៅពេលដែលយើងបានអង្ករចឹងទៅនៅពេលនឹងគឺយើងនឹងបានខ្វះអង្ករចឹងគឺខ្ញុំនឹងបានលក់បានបន្តិចបន្តួចអីនឹងបាន២០០០រៀលរឺក៏បាន៣០០០រៀលរបស់ខ្មែរយើងចឹងទៅហើយខ្ញុំនឹងក៏បានមកស្ដីចឹងទៅហើយនៅពេលដែលបានមកចឹងទៅខ្ញុំនឹងក៏បានទៅទិញហើយនឹងលក់ដូរទៀតចឹងទៅចាសនឹងហើយហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនបានចេះកាប់អូសហើយនឹងធ្វើឡហើយនឹងធ្វើឬស្សីនោះទេចាគឺខ្ញុំនឹងមិនចេះកាប់តែម្ដងហើយនៅពេលដែលខ្ញុំនឹងផ្លកនឹងគឺខ្ញុំនឹងចេះតែដើរលក់ដូរតាមភូមិកំពេចកំពុកនឹងទេចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងចេះធ្វើតៅហ៊ូរហើយនឹងដាក់វាតាមកញ្ជើលនឹងដើរមោនភូមិចឹងទេចាសហើយក៏បានលុយបន្តិចបន្តួចចឹងទៅហើយអាណាដែលយើងបានចំណេញចឹងទៅគឺយើងទុកសំរាប់ហូបចឹងទៅហើយអាណាដែលសំរាប់ដើមចឹងទៅគឺយើងទុក្ខនឹងសំរាប់លក់ដូតរទៅទៀតចឹងទៅហាសចាស៕

កៈ បាទហើយនៅក្នុងជំនាន់នឹងថាតើគេចាយលុយយ៉ាងមិចដែលទៅលោកយាយ???

ខៈ
ចាសវាភ្លេចបានហើយយើងនឹងរកនឹកមិនបានឃើញនោះទេចៅអើយចាសហើយខ្ញុំនឹងគឺវាភ្លេចមែនចឹងហាសចាសនិយាយទៅនៅពេលដែលខ្ញុំនឹងបាននិយាយនឹងគឺនៅក្នុងខ្លួននឹងចេះតែគិតហើយនេះចាសហើយនៅពេលដែលខ្ញុំនឹងបានគិតច្រើនចឹងគឺខ្ញុំនឹងគិតដូចជាមនុស្សឆ្កួតចឹងហាសចាសមែនតានៅពេលដែលខ្ញុំ
នឹងបានលើកយករឿងទាំងអស់នឹងយកមកនិយាយមកគឺខ្ញុំនឹងមានអាម្មរណ៏ថាឆ្អែតតែម្ដងហាសចាសនិយាយទៅគឺខ្ញុំនឹងឆ្អែតតែម្ដងចាស៕

កៈ
បាទហើយចឹងនៅពេលដែលគេបានរំដោះហើយចឹងលោកយាយបានរស់នៅខេត្តកំពង់ស្ពឺនឹងថាតើលោកយាយនៅពេលដែលលោកយាយបានរស់ខេត្តកំពង់ស្ពឺនឹងថាតើលោកយាយដែលបានឃើញពួកពោលពតអ្វីដែលគាត់បានដើរតាមផ្លូវដែលគេបានធ្វើបាប់លោកយាយដែលរឺទេលោកយាយ???

ខៈ
ចាសនិយាយទៅគឺខ្ញុំនឹងមិនដែលបានឃើញនោះទេចាសពីព្រោះអីនឹងគឺខ្ញុំនឹងមិនដែលបានដើរទៅក្នុងព្រៃនឹងផងហាសចាហើយនៅពេលដែលបានបែកនឹងគឺខ្ញុំនឹងរស់នៅតែនៅក្នុងភូមិនឹងនោះទេចាសនិយាយគឺខ្ញុំនឹងនៅតែភូមិទេពីព្រោះអីនឹងខ្ញុំនឹងមិនដែលបានដើរទៅណានោះទេចាសនិយាយទៅគឺខ្ញុំនឹងនៅតែផ្ទះហើយនឹងដើរលក់តាមភូមិចឹងហាសចាសគឺខ្ញុំនឹងដើរលក់ចឹងទៅហើយនៅពេលដែលលក់អស់ចឹងទៅហើយខ្ញុំនឹងក៏បានមកផ្ទះវិញចឹង

ទៅនិយាយទៅគឺខ្ញុំនឹងមិនដែលបានជួបពួកពោលពតនឹងនោះទេចាសគឺខ្ញុំនឹងមិនដែលបានជួបពួកពោលពតនឹងទេចាស៕

ក៖ បាទហើយចឹងនៅពេលដែលគេបានរំដោះជំនាន់ឆ្នាំ ១៩៧៩ ដែលជាជំនាន់ពោលពតនឹងថាតើលោកយាយមានអារម្មណ៍យ៉ាងមិចដែលទៅលោកយាយនៅពេលដែលគេបានរំដោះហើយចឹងហាសបាទ???

ខ៖
ចាសនិយាយទៅអារម្មណ៍របស់ខ្ញុំនឹងគឺមានភាពរីករាយហើយនឹងសប្បាយហើយនឹងនឹងបានគិតថាចាប់ពីថ្ងៃនឹងទៅគឺយើងនឹងបានរួចពីសេចក្ដីស្លាប់ហើយចឹងហាសចាសដែលនៅក្នុងជំនាន់នឹងហើយបាននឹកឃើញថាអាញ់ល្ងាចនឹងបានរស់ហើយសំរាប់ស្អែកនឹងតែមិនដឹងថាជាយ៉ាងមិចនោះទេហើយនៅពេលដែលយើងបានរស់មានជីវិតនឹងពេលល្ងាចនឹងហើយនឹងសំរាប់ថ្ងៃស្អែកក៏យើងនឹងមិនបានដឹងថាយ៉ាងមិចដែលទេចាសពីព្រោះអីយើងបានគិតថានៅពេលដែលយើងនឹងបានធ្វើខុសនឹងយើងនឹងមិនដឹងទៅជាយ៉ាងមិចនោះទេចាសតិចគេយកយើងនឹងទៅកសាងហើយគេយកយើងនឹងទៅពេលណាដែលចឹងហាសហើយយើងនឹងចេះតែគិតចឹងទៅចាសហើយនៅពេលដែលគេបានរំដោះហើយចឹងទៅគឺខ្ញុំនឹងមិនដែលបាននឹកឃើញការកសាងហើយនឹងលេងបាននឹកឃើញគេយកទៅវៃចោលវៃអីនឹងនិយាយទៅគឺយើងនឹងបានឃើញតែភាពសុខសាន្តហាសចាសចឹងបានថាយើងមានភាពសុខសាន្តហាសចាស៕

ក៖ បាទហើយចឹងនៅពែលដែលគេបានរំដោះលោកយាយពីឆ្នាំ ១៩៧៩ ដែលជាជំនាន់ពោលពតនឹងលោកយាយមានភាពសុខសាន្តហើយនឹងមានសេចក្ដីសប្បាយហើយនឹងរីករាយដែលបានរួចផុសពីសេចក្ដីស្លាប់ចឹងហាសមែនដែលទេលោកយាយ???

ខ៖
ចាសពេលនឹងគឺខ្ញុំនឹងមានភាពសុខសាន្តហើយនឹងមានសេចក្ដីសប្បាយហើយនឹងរីករាយដែលបានរួចផុសពីសេចក្ដីស្លាប់ចាសពីព្រោះអីនឹងនៅពេលដែលខ្ញុំនឹងនៅក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងបានគិតថាខ្ញុំនឹងបានរស់១ថ្ងៃហើយនឹងស្លាប់១ថ្ងៃចឹងហាសចាសហើយគេបានអោខ្ញុំនឹងបានឡើងទៅលើដើមត្នោតហើយខ្ញុំនឹងគឺបានឡើងទៅលើហើយខ្ញុំបានកាប់ស្លឹកត្នោតហើយសំរាប់ខ្ញុំនឹងក៏បានតស៊ូរចឹងទៅពីព្រោះអីនឹងខ្ញុំនឹងបានគិតថានៅពេលដែលខ្ញុំនឹងបានប្រកែកនឹងគេខ្លាចគេនឹងយកយើងនឹងទៅកសាងរឺក៏យកទៅវៃចោលចឹងហាសចាសនិយាយមិនទ្រឹមតែវៃដល់យើងនោះទេគឺវៃដល់ឪពុកហើយនឹងម្ដាយរបស់យើងទៀតចឹងហាសចឹងយើងចេះតែធ្វើចឹងទៅហាសចាស៕

ក៖
បាទហើយចឹងនៅពេលដែលយើងមិនបានធ្វើការងារនៅក្នុងជំនាន់នឹងគឺវៃដល់ឪពុកហើយនឹងម្ដាយរបស់យើងមែនដែលទេលោកយាយ???

ខ៖
ចាសចុះអានឹងគេបានថាយើងនឹងជំទោសនឹងអង្គការរបស់គេចឹងហាសហើយនឹងជំទាស់ហើយយើងនឹងគឺយើងជាក្មែកម្ចាស់ចឹងទៅចាសតែប្រសិនជាមិនយាយយក៏មានឈ្លបគេដើរលួបមើលចឹងហាសចាសហើយគឺមានឈ្លបគេនឹងដើរតាមផ្ទះរបស់យើងចឹងហាសចាសហើយនៅពេលដែលយើងនឹងហូបបាយឆ្ងាយរឺក៏មិនឆ្ងាយនឹងហើយនឹងបានហូបឆ្អែតនឹងក៏យើងនឹងមិនហៀននិយាយដែលចាសហើយនៅពេលដែលបានដេកគឺយើងនឹងគិតតែដេកហើយចាសគឺមិនដូចល្ងូវនឹងទេចាសហើយគេនឹងចង់និយាយដល់ម៉ោងប៉ុន្មានប៉ុន្មានក៏គ្មានអ្នកណាថាអីដែលចាសចង់និយាយអីនិយាយហើយល្ងូវនឹងចាសហើយនៅជំនាន់នោះអីនឹងនៅពេលដែលបានហូបបាយអីឆ្អែតអីនឹងគឺយើងនឹងបានចូលទៅដេកហើយអត់មាននយាយអីហើយនៅពេលដែលព្រឹកឡើងដឹងតែគេវៃអាកាំងម៉ាងម៉ាងចឹងទៅគឺយើងទាំងអស់គ្នានឹងក៏ចាប់ផ្តើមទៅស្ទុងហើយនឹងទៅដកចឹងទៅចាសហើយល្ងូវនឹងយើងនិយាយទៅដល់ម៉ោងប៉ុន្មានក៏គ្មានអ្នកណាថាអីដែលហើយយើងចង់ទៅដេកម៉ោងប៉ុន្មានក៏គ្មានអ្នកណាថាអីដែលចាសហើយឈ្លបនឹងវាតាមដានយើងទៀតនិយាយវាតាមយើងខ្លាំងណាស់៕

ខ៖
បាទហើយចឹងនៅក្នុងជំនាន់នឹងថាតើគេម៉ោងប៉ុន្មានដែលគេអោយយើងនឹងចូលដេកដែលគេកំណត់អោយតែម្តងហាសលោកយាយ???

ក៖ ចាសនៅពេលដែលយើងនឹងធ្វើការងារដូចជារ៉ែកហើយនឹងធ្វើជាទំនុបនឹងចាស
ម៉ោង១០រឺក៏ម៉ោង ១១ពេលថ្ងៃដែលម៉ោង ១១
នឹងគេអោយយើងឈប់សំរាប់នឹងដើម្បីស៊ីបាយហើយដែលជាពេលថ្ងៃនឹងហាសចាសថ្ងៃដែលយើងនឹងបានដកស្ទុងចាសហើយសំរាប់ពេលយប់នឹងក៏ចឹងដែលដល់ម៉ោង ១១
នឹងគឺគេអោយយើងនឹងឈប់ហើយនឹងបានសំរាប់ចឹងទៅ៕

ក៖ ម៉ោង ១១ យប់មែនលោកយាយ
បាទហើយនៅម៉ោងប៉ុន្មានទៀតដែលគេនឹងបានអោយយើងនឹងទៅធ្វើការងារវិញទៀតដែលទៅលោកយាយ???

ខ៖ ចាសនិយាយនៅពេលដែលម៉ោង ៧
ព្រឹកនឹងគេអោយយើងនឹងទៅហើយហើយប្រសិនជាស្រែកពេលថ្ងៃនឹងម៉ោង
៩នឹងគឺគេនឹងបានហៅយើងហើយអាកាំងគេដែលគេបានដាក់អោយយើងដើរទៅដកហើយនឹងដើរទៅស្ទុងនឹងហើយហើយសំរាប់សំពតរបស់យើងនឹងមានសុទ្ធតែដីហើយនឹងប្រលាក់ហើយយើងនឹងចេះតែទៅហើយចាស៕

ក៖
បាទហើយចឹងនិយាយទៅពីបាក់មែនទែនដែលនៅក្នុងជំនាន់ពោលពតនឹងលោកយាយ

ហើយចឹងសំណួរដែលខ្ញុំនឹងចង់សួរលោកយាយ១ទៀតថាតើនៅពេលដែលជំនាន់នឹងលោកយាយអត់មានបានរស់នៅជាមួយនឹងឪពុកហើនឹងម្ដាយរបស់លោកយាយនោះទេហើយសំរាប់លោកយាយបានរស់នៅជាមួយនឹងកូនរបស់លោកយាយបាទហើយពេលនឹងគឺលោកយាយបានបែកពីជំនាន់ពោលពតហើយចឹងលោកយាយនៅជាមួយនឹងស្វាមីរបស់លោកយាយដែលរឺក៏ម្នាក់ឯងរឺក៏រស់នៅជាមួយនឹងកូនរបស់លោកយាយដែលរឺក៏យ៉ាងមិចទៅលោកយាយអាចប្រាប់ខ្ញុំនឹងបានដែលរឺទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងបានរស់នៅជាមួយនឹងកូនរបស់ខ្ញុំនឹងហើយប្ដីរបស់ខ្ញុំនឹងគឺនិយាយទៅគឺខ្ញុំនឹងគឺមេម៉ាយតាំងពីខ្ញុំនឹងមានអាយុ ២៥
មកម្លេះដែលខ្ញុំនឹងបានប្រាប់ប្ដីរបស់ខ្ញុំនឹងគេចាប់យកទៅធ្វើជាទាហ៊ាននឹងនោះចាស៕

ក៖
បាទចឹងនៅពេលដែលលោកយាយនៅជាមួយនឹងកូនរបស់លោកយាយថាតើមានអ្នកណាដែលជាអ្នកផ្គត់ផ្គង់នៅកក្នុងក្រុមគ្រួសាររបស់លោកយាយដែលលោកយាយ???

ខ៖
ចាសគឺខ្លួនឯងតែម្ដងនិយាយគឺផ្គត់ផ្គង់ខ្លួនឯងតែម្ដងនិយាយទៅដោះស្រាយខ្លួនឯងអត់មានចាសពីព្រោះអីនឹងប្រសិនជាយើងនឹងទៅទីពឹងម្ដាយហើយនឹងឪពុកនឹងគឺគាត់ទាំង២មានកូនច្រើនដែលនិយាយទៅគឺទាំងហ្វូងដែលចឹងហាសចាសនិយាយទៅគឺកុំអោយគាត់ពិបាក់ដោយយើងហើងយើងអត់ស៊ីមានស៊ីតែយើងចឹងទៅចាសនឹងហើយ៕
ក៖
បាទហើយចឹងនៅក្នុងជំនាន់ថាតើលោកយាយប្រកបមុខរបបអ្វីដែលសំរាប់ចិញ្ចឹមជីវិតរបសលោកយាយទៅលោកយាយ???

ខ៖
ចាសនិយាយទៅគឺដូចខ្ញុំនឹងថាចឹងដូចថាខ្ញុំនឹងរកអីបន្តិចទៅហើយនឹងដើរហើយនឹងបេះស្អីស្អីចឹងទៅអោយតែបានលុយចឹងទៅហើយខ្ញុំនឹងបានទៅផ្សារទៅទិញប៊ីចេងហើយនឹងខ្លឹមហើយនឹងម្រិចដើរលក់ចឹងទៅដែលនៅក្នុងភូមិនឹងដែលខ្ញុំនឹងបាននិយាយនឹងចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងមិនបានចេះកាប់ឬស្សីហើយនឹងធ្វើឡរទេហើយសំរាប់គេដែលគេមានប្ដីប្រពន្ធនឹងគឺគេបាននាំគ្នាទៅកាប់ឬស្សីហើយនឹងអូសរទេះហើយនឹងបានធ្វើឡរចឹងទៅហើយនឹងបានចិញ្ចឹមជីវិតរបស់គេចឹងទៅហើយសំរាប់ខ្ញុំនឹងគឺអត់ទេគឺខ្ញុំនឹងអត់ចេះទេគឺខ្ញុំនឹងកាប់អត់កើតចាសគឺខ្ញុំនឹហាធ្វើវាមិនបានហើយសំរាប់ខ្ញុំនឹងមិនដឹងធ្វើយ៉ាងមិចហើយគ្រាន់តែកន្ទេលហើយនឹងអាកន្ទេលនឹងគឺខ្ញុំនឹងមិនចេះដេរហើយនឹងត្បាញទេចាសនិយាយទៅគឺខ្ញុំនឹងធ្វើមិនកើតហើយទាំមរាមតែខ្ញុំនឹងទៅកាប់ឬស្សីនឹងគឺខ្ញុំនឹងធ្វើវាមិនបានចាសហើយក៏មិនបានដឹងថាគេកាប់យ៉ាងមិចហើយនឹងចងយ៉ាងមិចលោកយាយទៅខ្ញុំនឹងចេះហើយដូច

ជាឡូរចឹងគឺខ្ញុំនឹងមិនដឹងថាគេជីកឡូរនឹងវាយ៉ាងមិចហើយនឹងរៀបយ៉ាងមិចនិយាយទៅគឺខ្ញុំនឹងមិនធ្វើនោះទេ៕

ក៖
ហ៊ីមពិបាក់ចឹងខ្ញុំនឹងសួរតែ១សំណួរពីក៏២សំណួរទៀតទេលោកយាយចឹងតាំងពីជំនាន់ពោលពតរហូតមកដល់សព្វថ្ងៃនេះចឹងលោកយាយបានរស់នៅភូមិអ្វីស្រុកអ្វីហើយនឹងខេត្តអ្វីដែលទៅលោកយាយ???

ខ៖
ចាសនិយាយទៅគឺខ្ញុំនឹងនៅខេត្តដ៏ដែលនឹងភូមិក្រាំងអំពើលស្រុកសំរោងទងហើយនឹងខេត្តកំពុងស្ពឺហើយសំរាប់ភូមិនឹងគឺភូមិក្រាំងអំពើលហើយនឹងស្រុកសំរោងទងដចាសដែលអ្នកឯងនឹងបានជួបនឹងចាសហើយសំរាប់ខ្ញុំនឹងនៅភូមិក្រាំងអំពើលដ៏ដែលនឹងគ្រាន់តែនៅស្រុកសំរោងទេខេត្តកំពុងស្ពឺ៕

ក៖
បាទហើយចឹងលោកយាយរស់នៅទីវត្តអារាមនឹងតែម្នាក់ឯងទេមែនដែលទេលោកយាយ???

ខ៖ ចាសនិយាយទៅគឺខ្ញុំនឹងរស់នៅតែម្នាក់ឯងទេចៅ៕

ក៖
បាទហើយចឹងកូនចៅរបស់លោកយាយមានដែលបានមកលេងលោកយាយដែលលោកយាយដែលរឺទេ???

ខ៖
ចាសល្ងូវនឹងគឺគេនឹងបានរវល់នឹងការងាររបស់គេចឹងហាសចាសហើយគេនឹងមិនដែលបានមកលេងយើងនោះទេចាស៕

ក៖ បាទហើយចឹងពួកគាត់ធ្វើការងារអ្វីដែលទៅលោកយាយ???

ខ៖
ចាសកូនចៅរបស់ខ្ញុំនឹងគឺគេទៅធ្វើការងាររោងចក្រនឹងហាសចៅហើយនៅពេលដែលគេចេញពីរោងចក្រចឹងទៅគេទៅផ្ទះរបស់គេចឹងទៅចាស៕

ក៖ ហើយចឹងគឺពួគេនឹងមិនបានដែលមកលេងលោកយាយទេមែនដែលទេលោកយាយ???

ខ៖
ចាសនិយាយទៅគឺមិនដែលមកលេងខ្ញុំនឹងនោះទេពីព្រោះអីនឹងគឺខ្ញុំនឹងមិនដែលបានចឹង

ហាសហើយនៅពេលដែលគេមកមិនមកក៏មិនអីចឹងហាសចាសវាដូចតែគ្នានោនះទេហើយ
សំរាប់ខ្ញុំនឹងមិនដែលបាននឹងទូចចិត្តអីនោះទេចាស៕

កៈ
បាទហើយចឹងសំណួរដែលខ្ញុំនឹងចង់សួរទៅកាន់លោកយាយហើយក៏ជាសំណួរចុងក្រោយ
ទៅកាន់លោកយាយថាតើលោកយាយមានអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់លោកយាយដែ
លរឺទេនៅពេលដែលពួកគេបានលឺសំលេងរបស់លោកយាយពីជីវភាពលំបាក់របស់លោក
យាយដែលនៅក្នុងជំនាន់ពោលពតហើយនឹងការតស៊ូហើយនឹងភាពលំបាក់ថាតើលោក
យាយមានអ្វីផ្ដែលផ្ដាំទៅកាន់កូនចៅរបស់លោកយាយហើយនឹងចៅទួតរបស់លោកយាយ
ថាតើលោកយាយមានអ្វីផ្ដែលផ្ដាំទៅកាន់ពួកនៅពេលដែលពួកគាត់បានលឺនឹងពាក្យពេជ្រ
របស់លោកយាយដែលរឺទេលោកយាយ???

ខៈ
ចាសសំរាប់ខ្ញុំនឹងគ្មានអ្វីផ្ដែលផ្ដាំនោះទេគ្រាន់តែផ្ដែលផ្ដាំថានៅក្នុងជំនាន់នឹងវាពីបាក់ហើយ
ខ្ញុំនឹងតស៊ូដើម្បីរស់ហើយនឹងមានភាពពីបាក់ដែលនៅក្នុងជីវិតរបស់ខ្ញុំនឹងចាសហាសចាស
ហើយសុំអោយកូនចៅហើយនឹងមានសុខសប្បាយអោយតរៀងទៅគឺអោយបានសុខសាន្ត
ហាសចាសអោយបានកូនចៅរបស់ខ្ញុំនឹងចាសពីព្រោះអីនឹងកាល់ដែលខ្ញុំនឹងនៅជំនាន់នៅ
ក្នុងជំនាន់ពោលពតនឹងគឺខ្ញុំនឹងរស់នៅវាឆ្អែតហើយចាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំបានដើរកា
ប់ដើមត្នោតហើយនឹងមានភាពលំបាក់ណាស់ចាសហើយនៅពេលដែលគេអោយខ្ញុំនឹងអោ
យដាំទឹកហើយពេលនឹងគឺគេអោយខ្ញុំនឹងធ្វើជ្រូកចឹងហាសហើយសំរាប់ខ្ញុំនឹងគឺខ្ញុំនឹងថាខ្ញុំនឹ
ងមិនបានធ្វើនោះទេចាសដាំហើយនឹងដាក់នៅតាមខ្លួនរបស់ខ្ញុំនឹងអីចឹងហាសចាសអង្គការ
របស់កាណាក់កងរបស់គេហើយគេបានប្រាប់ថាមិត្តនារីឯងនឹងដាំទឹកទៅហើយសំរាប់ខ្ញុំនឹ
ងគឺបានប្រាប់ដាំទឹកធ្វើអីនឹងហើយនៅពេលដែលគេបានអោយខ្ញុំនឹងដាំទឹកធ្វើគឺខ្ញុំនឹងបាន
និយាយថាខ្ញុំមិនដាំនោះទេហើយប្រសិនជាខ្ញុំនឹងដាំទឹកនឹងសុំអោយស្រល់ខ្ញុំនឹងជាមួយនឹង
សត្វជ្រូកនឹងជាមួយនឹងគ្នាទៅហាសចាសហើយប្រសិនជាអោយខ្ញុំនឹងស្រល់ជ្រូកនឹងធ្វើម្ហូ
បនឹងអោយអូនឯងនឹងស្រស់ជ្រូកនឹងជាមួយនឹងខ្ញុំទៅហាសចាសគឺខ្ញុំនឹងហ៊ានតជាមួយនឹ
ងគេនឹងម្ដងចាសហាសហើយខ្ញុំនឹងបាននិយាយថាប្រសិនជាជីវិតរបស់ខ្ញុំនឹងស្លាប់ក៏ស្លាប់
ទៅចុះពីព្រោះអីនឹងសាច់ជ្រូកនឹងដូចខ្ញុំនឹងបានប្រាប់អូនឯងគឺចៅឯងថាពីមុននឹងគឺថាខ្វះនឹ
ងមិនហូបនោះទេចាសសាច់ជ្រូកដល់ពេលដែលខ្ញុំនឹងបានលឺសាច់ជ្រូកស្រែកចាសគឺខ្ញុំនឹង
តែតែងលឺសាច់ជ្រូកនឹងស្រែកដាក់ត្រចៀករបស់ខ្ញុំនឹង៕

កៈ
បាទលោកយាយចឹងលោកយាយមានអ្វីដែលផ្ដែលផ្ដាំទៅកាន់កូនចៅរបស់លោកយាយប
ន្ថែមទៀតដែលរឺទេនៅពេលដែលគាត់អាចមានឪកាសដើម្បីលឺសំលេងរបស់លោកយាយ
ដើម្បីអោយគាត់បានគោរពលោកយាយដើម្បីមានឪកាសមកលេងលោកយាយមានអ្វីដែ
លផ្ដែលផ្ដាំទៀតដែលរឺទេលោកយាយ???

ខ៖ ចាសគឺគ្មានអ្វីដែលផ្ដែលផ្ដាំអ្វីទៀតនោះទេអូនទេចាស៕

ក៖
បាទហើយចឹងថ្ងៃនឹងចៅមានតែប៉ុននឹងលោកយាយថ្ងៃនឹងខ្ញុំអរគុណមែនទែនសំរាប់ការពិភាពសារហើយនឹងមានឪកាសអោយខ្ញុំនឹងបានសំភាសន៍លោកយាយអំពីជីវប្រវត្តរបស់លោកយាយអំពីការលំបាក់ដែលលោកយាយនៅក្នុងជំនាន់ពោលពតអរគុណសំរាប់ការផ្តល់សំរាប់ការពិភាពសារថ្ងៃនេះផងដែលចឹងថ្ងៃនឹងខ្ញុំមានតែប៉ុននឹងទេលោកយាយចឹងអរគុណច្រើនមែនទែនលោកយាយចឹងខ្ញុំនឹងជំរាបលាណាលោកយាយ៕